ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានរដ្ឋបាល

លេខ: ០១៤ ន.ប.ក/រ.ត.ន.ប

ថ្ងៃ... ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែធ្នូ គ.ស ២០១៨

នាយកដ្ឋានបណ្តុះបណ្តាល
ចូល លេខ... ម៉ោង ១០:៣០ ថ្ងៃទី ១១ ខែ ១២ ឆ្នាំ ២០១៨ បញ្ជូន...

# របាយការណ៍
## ស្តីពី
## សកម្មភាព និងលទ្ធផលការងារប្រចាំខែវិច្ឆិកា និងទិសដៅការងារបន្ត សម្រាប់ខែធ្នូ ឆ្នាំ២០១៨ របស់អគ្គនាយកដ្ឋានរដ្ឋបាល

អគ្គនាយកដ្ឋានរដ្ឋបាល គឺជាអង្គភាពមួយក្នុងចំណោមអង្គភាពទាំង១១ ចំណុះក្រសួងមហាផ្ទៃ មានតួនាទីជាសេនាធិការឱ្យក្រសួង ក្នុងការអនុវត្តច្បាប់រៀបចំអង្គការពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៦ នៃរដ្ឋសភា ព្រមទាំងសម្របសម្រួលក្នុងការបង្កើត ការចុះបញ្ជី និងគ្រប់គ្រងសកម្មភាពសមាគម អង្គការមិនមែនរដ្ឋាភិបាល និងគណបក្សនយោបាយ។

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៨នេះ អគ្គនាយកដ្ឋានរដ្ឋបាលបានអនុវត្តការងារតាមតួនាទី ភារកិច្ចដោយ សម្រេចលទ្ធផលបានដូចខាងក្រោម៖

### I-សកម្មភាពការងារ និងលទ្ធផល

#### ១-ការងារលិខិតស្នាម និងឯកសារផ្សេងៗ

-បានទទួលលិខិត និងឯកសារ ដែលបញ្ជូនមកពីអគ្គលេខាធិការដ្ឋាន និងអង្គភាពនានាចំណុះក្រសួងមហាផ្ទៃ សរុបចំនួន ៦៤៩ច្បាប់ និងបានធ្វើការបែងចែកជូនទៅនាយកដ្ឋានចំណុះរួមមាន៖ នាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន ២២៨ច្បាប់ នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន ៣៩ច្បាប់ នាយកដ្ឋានបុគ្គលិកចំនួន ២១៨ច្បាប់ នាយកដ្ឋានបណ្តុះបណ្តាលចំនួន ២៨ច្បាប់ នាយកដ្ឋានមុខងារ និងធនធានចំនួន ៥៨ច្បាប់ និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន ៧៨ច្បាប់។

-បានទទួលលិខិត មកពីនាយកដ្ឋានជំនាញចំណុះអគ្គនាយកដ្ឋានរដ្ឋបាលមានចំនួន ៣៨៨ច្បាប់ ដែលក្នុងនោះមកពីនាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន ៩០ច្បាប់ នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន ១២ច្បាប់ នាយកដ្ឋានបុគ្គលិកចំនួន ១៧៥ច្បាប់ នាយកដ្ឋានបណ្តុះបណ្តាលចំនួន ៣៣ច្បាប់ នាយកដ្ឋានមុខងារ និងធនធានចំនួន ៣៦ច្បាប់ និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន ៤២ច្បាប់ ដើម្បីដាក់ជូនអគ្គនាយកជ្រាបជារបាយការណ៍និងពិនិត្យ សម្រេច។

-បានចាត់ចែងបញ្ជូនឯកសារចំនួន ២២៤ច្បាប់ ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងជ្រាបជារបាយការណ៍និងពិនិត្យ សម្រេច ដែលក្នុងនោះឯកសារមកពីនាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន ៧០ច្បាប់ នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន ០៧ច្បាប់ នាយកដ្ឋានបុគ្គលិកចំនួន ៧៤ច្បាប់ នាយកដ្ឋានបណ្តុះបណ្តាលចំនួន ១៣ច្បាប់ នាយកដ្ឋានមុខងារ និងធនធានចំនួន ២៥ច្បាប់ និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន ៣៥ច្បាប់។

-បានទទួលឯកសារចំនួន ១៨៥ច្បាប់ ដែលថ្នាក់ដឹកនាំក្រសួងមហាផ្ទៃពិនិត្យ សម្រេចរួច និងបញ្ជូនទៅនាយកដ្ឋានចំណុះដើម្បីចាត់ចែងបន្តរួមមាន៖ នាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន ៣៥ច្បាប់ នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន ០៣ច្បាប់ នាយកដ្ឋានបុគ្គលិកចំនួន ៩៦ច្បាប់ នាយកដ្ឋានបណ្តុះបណ្តាលចំនួន ១១ច្បាប់ នាយកដ្ឋានមុខងារ និងធនធានចំនួន ២០ច្បាប់ និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន ២០ច្បាប់។

**២-ការងារចេញលិខិតបង្គាប់ការ និង លិខិតបញ្ជាបេសកកម្ម**

អគ្គនាយកដ្ឋានរដ្ឋបាលបានចេញលិខិតបង្គាប់ការ និងលិខិតបញ្ជាបេសកកម្មសរុបចំនួន ១២៤ច្បាប់ ក្នុងនោះ លិខិតបង្គាប់ការចំនួន ៥៦ច្បាប់ និងលិខិតបញ្ជាបេសកកម្មចំនួន ៦៨ច្បាប់ ជូនថ្នាក់ដឹកនាំ និងមន្ត្រីចំណុះអគ្គនាយកដ្ឋានរដ្ឋបាល ដើម្បីចុះទៅបំពេញបេសកកម្មនៅតាមបណ្តាខេត្តនានា។ ជាមួយគ្នានោះដែរ អគ្គនាយកដ្ឋានរដ្ឋបាលក៏បានចុះទិដ្ឋាការជូនមន្ត្រីរាជការមកពីបណ្តាខេត្តដែលមកបំពេញបេសកកម្មនៅក្រសួងមហាផ្ទៃផងដែរ។

**៣-ការងារប្រជុំ និងសិក្ខាសាលាផ្សេងៗ**

ក្នុងខែវិច្ឆិកា ឆ្នាំ២០១៨ អគ្គនាយកដ្ឋានរដ្ឋបាល បានរៀបចំកិច្ចប្រជុំ និងចាត់មន្ត្រីចូលរួមកិច្ចប្រជុំ សិក្ខាសាលា បឋកថា សន្និសីទ ជាវគ្គិន និងកម្មវិធីនានាដូចខាងក្រោម៖

▪ ចូលរួមជាមួយសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងឱកាសអនុញ្ញាតឱ្យ៖

-ឯកឧត្តម ប៊ួយ វ៉ាន់ណាម អនុរដ្ឋមន្ត្រីក្រសួងនគរបាលវៀតណាម ចូលជួបសម្តែងការគួរសម

-ឯកឧត្តម **Sudirman Haseng** ឯកអគ្គរដ្ឋទូតឥណ្ឌូនេស៊ីទើបតែងតាំងថ្មីប្រចាំកម្ពុជាចូលជួបសម្តែងការគួរសម

-លោកស្រី **Rhona Smith** អ្នករាយការណ៍ពិសេស អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស នៅកម្ពុជាចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ។

▪ ការប្រជុំ សិក្ខាសាលា៖

-ចូលរួមក្នុងកិច្ចប្រជុំពិភាក្សា អំពីការព្រួយបារម្ភរបស់ប្រទេសមួយចំនួនពាក់ព័ន្ធសភាពការណ៍កម្ពុជា នៅទីស្តីការក្រសួងមហាផ្ទៃ

-ចូលរួមក្នុងកិច្ចប្រជុំជាមួយគណៈប្រតិភូអន្តរក្រសួង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅទីស្តីការក្រសួងមហាផ្ទៃ

-ចូលរួមក្នុងកិច្ចប្រជុំរាយការណ៍ស្តីពី លទ្ធផលនៃការសិក្សាកែទម្រង់រចនាសម្ព័ន្ធគ្រប់គ្រងនៅថ្នាក់ក្រុង ស្រុក និងលទ្ធផលនៃការពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីការបង្កើនថវិកាទៅឱ្យរដ្ឋបាលឃុំ សង្កាត់

-ចូលរួមកិច្ចប្រជុំស្តាប់របាយការណ៍ស្តីពីលទ្ធផលនៃការសិក្សាស្រាវជ្រាវធ្វើវិសោធនកម្មច្បាប់ព្រៃឈើ ច្បាប់តំបន់ការពារធម្មជាតិ និងច្បាប់ជលផល

-ចូលរួមក្នុងកិច្ចប្រជុំស្តីពីវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការកម្ពុជា-វៀតណាម

-ចូលរួមកិច្ចប្រជុំស្តីពីលទ្ធផលនៃការផ្លាស់ប្តូរព័ត៌មាន និងពិភាក្សាការងាររវាងគណៈប្រតិភូអគ្គនាយកដ្ឋានអន្តោប្រវេសន៍កម្ពុជា ជាមួយក្រសួងនគរបាល និងក្រសួងការពារជាតិវៀតណាម

-ចូលរួមក្នុងកិច្ចប្រជុំពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិ នៃគម្រោងភាពជាដៃគូសម្រាប់គំនិតច្នៃប្រឌិតរបស់ទីក្រុងក្នុងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន (PMI-LED) រាជធានីភ្នំពេញ

-ចូលរួមកិច្ចប្រជុំពិភាក្សាអំពីការពង្រឹង និងគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ

-ចូលរួមកិច្ចប្រជុំវាយតម្លៃសំណើគម្រោងមូលនិធិគំនិតច្នៃប្រឌិត នៅមូលដ្ឋាន (LIF)នៃគម្រោងភាពជាដៃគូសម្រាប់គំនិតច្នៃប្រឌិតរបស់ទីក្រុងក្នុងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន នៅបន្ទប់ប្រជុំអគ្គលេខាធិការដ្ឋានសមគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិក្នុងបរិវេណព្រឹទ្ធសភា

-ចូលរួមកិច្ចប្រជុំ ពិនិត្យ ពិភាក្សា លើធាតុចូលសម្រាប់ដាក់បញ្ចូលក្នុងគោលនយោបាយជាតិប្រជាជន ឆ្នាំ២០១៦-២០៣០ និងផែនការណ៍យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣

-ចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងាររយៈពេល៩ខែឆ្នាំ២០១៨ និងផ្សព្វផ្សាយរបាយការណ៍លទ្ធផលការងាររយៈពេល៥ឆ្នាំ ២០១៤-២០១៨ របស់បេឡាជាតិរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

-ចូលរួមប្រជុំពេញអង្គស្តីពីការពិនិត្យ និងអនុម័តលើសេចក្តីព្រាងលក្ខន្តិកៈ និងគណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិចកួយ នៅខេត្តក្រចេះ

-ចូលរួមកិច្ចប្រជុំថ្នាក់ដឹកនាំបច្ចេកទេស លើការពិនិត្យកែសម្រួលកែសម្រួល សេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម នៅទីស្តីការក្រសួងមហាផ្ទៃ

-ចូលរួមកិច្ចប្រជុំពិភាក្សាលើការរៀបចំដំឡើងបៀវត្សសម្រាប់មន្ត្រីរាជការស៊ីវិលក្នុងឆ្នាំ២០១៩

-ចូលរួមកិច្ចប្រជុំលើកទី១០ក្រុមការងាររេដបូកជាតិ នៅសណ្ឋាគារអប្សរាអង្គរ ខេត្តសៀមរាប

-ចូលរួមកិច្ចប្រជុំអន្តរក្រសួង ស្តីពីការឧបត្ថម្ភសាច់ប្រាក់សម្រាប់ស្ត្រីមានផ្ទៃពោះ និងកុមារ នៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-ចូលរួមកិច្ចប្រជុំក្រុមការងារវាយតម្លៃអញ្ញមញ្ញ ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងចូលរួមប្រជុំជាមួយតំណាងក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់(APG) ដើម្បីរៀបចំយុទ្ធសាស្ត្រជាតិស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មឆ្នាំ២០១៩-២០២៣

-ចូលរួមពិគ្រោះយោបល់លើសៀវភៅសេចក្តីណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការទទួល និងការសម្រុះសម្រួលដោះស្រាយបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត

-ចូលរួមជាគ្រូសម្រួលវគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងសម្រាប់នាយករដ្ឋបាលក្រុង ស្រុក ខណ្ឌ របស់ សាលាជាតិរដ្ឋបាលមូលដ្ឋាន (NASLA)

-បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ លើសេចក្តីព្រាងសេចក្តីណែនាំស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលស្រុកដែលពុំមានការិយាល័យច្រកចេញចូលតែមួយ

-បានរៀបចំប្រជុំផ្សព្វផ្សាយអំពីនីតិវិធីនៃការជ្រើសរើសបុគ្គលិកសម្រាប់បំពេញការងារនៅការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋដល់ស្រុកគោលដៅចំនួន៣១ក្នុងឆ្នាំ២០១៨

-បានរៀបចំកិច្ចប្រជុំពិភាក្សាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការត្រៀមរៀបចំវគ្គបណ្តុះបណ្តាលបច្ចេកទេស នៃការផ្តល់សេវាដល់មន្ត្រីអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត

-បានរៀបចំកិច្ចប្រជុំគណៈកម្មការមេប្រយោគនៅតាមមណ្ឌលប្រឡង និងនាំវិញ្ញាសាទៅកាន់មណ្ឌលប្រឡងសម្រាប់ការប្រឡងជ្រើសរើសបេក្ខជនបញ្ចូលក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ សម្រាប់ឆ្នាំ២០១៨

-បានរៀបចំកិច្ចប្រជុំគណៈកម្មការកែវិញ្ញាសារ សម្រាប់ការប្រឡងជ្រើសរើសបេក្ខជនបញ្ចូលក្នុងក្របខ័ណ្ឌ

-ចូលរួមសិក្ខាសាលាមន្ត្រីរដ្ឋបាលជាន់ខ្ពស់ស្តីពី ភាពជាអ្នកដឹកនាំ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន

-ចូលរួមសិក្ខាសាលាពិគ្រោះយោបល់អន្តរក្រសួងកម្រិតបច្ចេកទេស លើសេចក្តីព្រាងផែនការសកម្មភាពឆ្នាំ២០១៩-២០២១ នៃគោលនយោបាយជាតិប្រជាជនឆ្នាំ២០១៦-២០៣០នៅសណ្ឋាគាកាំបូឌីយ៉ាណា ដែលរៀបចំដោយក្រសួងផែនការ

-ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីបច្ចុប្បន្នភាពយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដើម្បីរៀបចំគោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍន៍តំបន់ឆ្នេរ និងសមុទ្រប្រកបដោយចីរភាពនៅកម្ពុជា នៅសណ្ឋាគារភ្នំពេញ រៀបចំដោយក្រសួងបរិស្ថាន

-ចូលរួមសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍សិក្សាអំពីមុខងារ រចនាសម្ព័ន្ធ ការបំពេញមុខងារ និងការបំពេញមុខងាររបស់អង្គភាពធនធានមនុស្ស នៅថ្នាក់ជាតិ និងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

-ចូលរួមសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "ផែនការមេការតភ្ជាប់អាស៊ានឆ្នាំ២០២៥" នៅខេត្តសៀមរាប

-ចូលរួមសិក្ខាសាលាចែករំលែកបទពិសោធន៍ស្តីអំពីការផ្តល់សេវាបរិយាប័ន្នមុខរបរ នៅមូលដ្ឋានរយៈពេល ០៣ថ្ងៃ នៅខេត្តកំពង់ចាម

-ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការអភិវឌ្ឍសៀវភៅណែនាំការពារសុវត្ថិភាព និងបរិស្ថាន និងសៀវភៅអប់រំសុខភាពខ្លី សម្រាប់ជនជាតិដើមភាគតិច នៅខេត្តកំពង់ឆ្នាំង

▪ កម្មវិធីផ្សេងៗ៖

-ចូលរួមពិធីប្រកាសចូលកាន់តំណែង អភិបាល អភិបាលរង នៃគណៈអភិបាលខេត្តកំពត កំពង់ធំ ឧត្តរមានជ័យ និងខេត្តស្វាយរៀង

-ចូលរួមទិវាបុណ្យឯករាជ្យជាតិ ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៨ និងពិធីពន្លត់ភ្លើងជ័យ នាថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៨

-ចូលរួមកម្មវិធីរិប្បនា( Retreat Program )សម្រាប់វគ្គបណ្តុះបណ្តាលគ្រូបង្គោលឆ្នាំ២០១៨នៅខេត្តកែប។

-ចូលរួមជាអធិបតីក្នុងពិធីបើកវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងសម្រាប់នាយករដ្ឋបាលក្រុង ស្រុក ខណ្ឌ

-ចូលរួមគោរពវិញ្ញាណក្ខន្ធ និងគោរពព្រះវិញ្ញាណក្ខន្ធព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យបូរណភាពទឹកដី និងឯកភាពជាតិខ្មែរ( ព្រះបរមរតនកោដ្ឋ ) នៅវិមានឯករាជ្យ និងនៅសួនច្បារខាងកើតវិមានឯករាជ្យ

-ចូលរួមសន្និសីទតំបន់ស្តីពី "ទំនាក់ទំនងនៅឧបទ្វីបកូរ៉េក្នុងឆ្នាំ២០១៨ និងពេលខាងមុខ៖ គថភាព និងបញ្ហាប្រឈមថ្មី"នៅសណ្ឋាគារ៉ាហ្វលឡឺរ៉ូយ៉ាល់ភ្នំពេញ រៀបចំដោយវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

-ចូលរួមក្នុងពិធីបិទសន្និសីទថ្នាក់តំបន់ស្តីពី "ការប្រយុទ្ធប្រឆាំងឱសថក្លែងក្លាយ និងអន់គុណភាព"

-ចូលរួមទស្សនៈកិច្ចសិក្សាស្វែងយល់អំពីរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រង រដ្ឋបាលមូលដ្ឋាន នៃសាធារណរដ្ឋប្រជាមានិតចិន នៅសាធារណរដ្ឋប្រជាមានិតចិន

-ចូលរួមជាវាគ្មិនក្នុងអង្គសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការអនុវត្តច្បាប់ អនុក្រឹត្យ និងគោលនយោបាយជាតិដែលពាក់ព័ន្ធ នឹងការចុះបញ្ជីដីកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច នៅខេត្តរតនគិរី

-ចូលរួមបឋកថាកិត្តិយសស្តីពី "Seeking Refuge – Lessons from the past and present for the refugee cirses of the future" នៅសណ្ឋាគារ៉ាហ្វល ឡឺរ៉ូយ៉ាល់ភ្នំពេញ រៀបចំដោយវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព

-ចូលរួមបឋកថាកិត្តិយសស្តីពី "Mahathir 2.0 and Malaysia Evolving China policy: the Politics of renegotiation នៅសណ្ឋាគារ សាន់ វេ រៀបចំដោយវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព។

**៤-ការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត**

**៤.១-លិខិតបទដ្ឋានគតិយុត្តផ្ទៃក្នុងសម្រេចបាន**

-ប្រកាសលេខ ៦៦០៦ ប្រក ចុះថ្ងៃសុក្រ ២រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការអភិវឌ្ឍន៍សមត្ថភាពរបស់មន្ត្រីរាជការស៊ីវិល នៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីសម្រេចលេខ ៦៤២៤ សសរ ចុះថ្ងៃព្រហស្បត្តិ៍ ៣រោច ខែភទ្របទ ឆ្នាំ សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនិងថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការបង្កើតក្រុមការងារគាំទ្រដល់រដ្ឋបាលខេត្តព្រះសីហនុ

-សេចក្តីសម្រេចលេខ ៧៧ សសរ ចុះថ្ងៃអង្គារ ៦រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ របស់រាជរដ្ឋាភិបាលស្តីពីការកំណត់កាលបរិច្ឆេទការបោះឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាណត្តិទី៣

-សេចក្តីសម្រេចលេខ ៦៦០៥សសរ ចុះថ្ងៃសុក្រ ២រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ត្រូវនឹងថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិលនៅក្រសួងមហាផ្ទៃ និងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីណែនាំលេខ០៤០ សណន ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ស្តីពីកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយសមាគម អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ព្រមទាំងសហគមន៍នានា នៅមូលដ្ឋាន។

**៤.២-លិខិតបទដ្ឋានគតិយុត្តផ្ទៃក្នុងដែលកំពុងរៀបចំ**

-សេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋានការងាររបស់មន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះក្របខណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់អាសនៈក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌអាណត្តិទី៣

-សេចក្តីព្រាងអនុក្រឹត្យស្តីពីគោលការណ៍ និងនីតិវិធីនៃការបង្កើត ការលុបចោល ការកែសម្រួល និងការកំណត់ឈ្មោះរបស់រដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីរបៀបរបបធ្វើការងាររបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលស្រុកដែលពុំទាន់មានការិយាល័យច្រកចេញចូលតែមួយ

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីនីតិវិធីនៃការផ្លាស់ប្តូរ និងតែងតាំងស្មៀនឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីនីតិវិធីនៃការសុំច្បាប់ឈប់សម្រាករបស់ប្រធានក្រុមប្រឹក្សានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីបែបបទ និងនីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីការចេញប័ណ្ណសម្គាល់ខ្លួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាងសៀវភៅណែនាំស្តីពីនីតិវិធីនៃការសម្រុះសម្រួលដោះស្រាយបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋ

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីនីតិវិធីបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាងសៀវភៅកិច្ចការរដ្ឋបាលសម្រាប់ប្រើប្រាស់នៅតាមអង្គភាព(ផ្នែករដ្ឋបាលស៊ីវិល) ចំណុះទីស្តីការក្រសួងមហាផ្ទៃ។

**៤.៣-លិខិតបទដ្ឋានគតិយុត្តដែលកំពុងសហការរៀបចំជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ**

- សេចក្តីព្រាងច្បាប់ស្តីពីសេវាសាធារណៈ

- សេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម

- សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃអង្គរដ្ឋបាលសម្រាប់មន្ត្រីរាជការស៊ីវិល

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រង ការបែងចែកចំណូលពីកម្រៃសេវារដ្ឋបាលរបស់អង្គភាពច្រកចេញចូលតែមួយ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែប្រែ និងដំឡើងប្រាក់បំណាច់មុខងារជូនមន្ត្រីរាជការស៊ីវិល ឆ្នាំ២០១៩

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការដំឡើងប្រាក់បំណាច់មុខងារជូនមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការពិន័យអន្តរកាលចំពោះអំពើល្មើសនឹងអនុក្រឹត្យលេខ១១៣ស្តីពីការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន

-សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពី ការចុះបញ្ជីសហព័ន្ធអាជីវកម្ម ឬ ពាណិជ្ជកម្ម ឬសភាពាណិជ្ជកម្មបរទេស(ក្រសួងមហាផ្ទៃ និងក្រសួងពាណិជ្ជកម្ម)

-សេចក្តីព្រាងក្រមប្រតិបត្តិសម្រាប់អ្នករាជការសាធារណៈ

-សេចក្តីព្រាងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៩- ២០២៨។

## ៥-ការងារបុគ្គលិក

### ៥.១-ការងារក្របខ័ណ្ឌ

គិតត្រឹមខែវិច្ឆិកាឆ្នាំ២០១៨ ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល មន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃសរុបមានចំនួន **១៣.២៣៦នាក់/ស្រី ៣.២៩៨នាក់** ក្នុងនោះ(ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិចំនួន ៩៨៩នាក់/ស្រី ២២៧នាក់ ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលថ្នាក់ក្រោមជាតិចំនួន ៩.៣៣២នាក់/ស្រី ២.៦៨១នាក់ ក្របខ័ណ្ឌមន្ត្រីពន្ធនាគារថ្នាក់ជាតិចំនួន ១.១៨២នាក់/ស្រី១៨៤នាក់ ក្របខ័ណ្ឌមន្ត្រីពន្ធនាគារថ្នាក់ក្រោមជាតិចំនួន១.៧៣៣នាក់/ស្រី ២០៦នាក់) បើប្រៀបធៀបទៅនឹងខែតុលា ឆ្នាំ២០១៨ ក្របខ័ណ្ឌកើនឡើងចំនួន ០៥នាក់/ស្រី០២នាក់ ។ ជាមួយគ្នានេះដែរ ក្រសួងមហាផ្ទៃក៏បានបញ្ចូលក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ដែលបានផ្ទេរចូលពីក្របខ័ណ្ឌក្រសួងនានាចំនួន១៤នាក់/ស្រី០៣នាក់ផ្ទេរក្របខ័ណ្ឌចេញពីក្រសួងមហាផ្ទៃចំនួន ០៩នាក់/ស្រី០១នាក់ ក្នុងនោះផ្ទេរទៅក្នុងក្របខ័ណ្ឌក្រសួងនានាចំនួន០៦នាក់ លុបឈ្មោះដោយដាក់វិន័យដោយបញ្ញត្តិរយៈពេល០៣ខែចំនួន ០១នាក់ និងលុបឈ្មោះដោយមរណភាពចំនួន០២នាក់/ស្រី០១នាក់។

### ៥.២-ការងារគោលនយោបាយមន្ត្រីរាជការស៊ីវិល

ក្នុងខែវិច្ឆិកាឆ្នាំ២០១៨នេះ ក្រសួងមហាផ្ទៃបានអនុញ្ញាតឱ្យមន្ត្រីរាជការឈប់សម្រាកពីការងារចំនួន **១៣នាក់/ស្រី ១១នាក់** ក្នុងនោះ (សម្រាកលំហែមាតុភាព ០៩នាក់ ស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ០៤នាក់/ស្រី០២នាក់) បានអនុញ្ញាតឱ្យមន្ត្រីរាជការសុំចូលបម្រើការងារក្នុងអង្គភាពដើមវិញបន្ទាប់ពីស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សបៀវត្សចំនួន ០៤នាក់។

ទន្ទឹមនេះថ្នាក់ដឹកនាំក្រសួង ក៏បានផ្តល់គ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការស៊ីវិលថ្នាក់ក្រោមជាតិចំនួន ១៦៦នាក់ ក្នុងនោះគ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជាតាមលំដាប់ថ្នាក់ចំនួន**២៦គ្រឿង** រួមមាន(ថ្នាក់មហាសេរីវឌ្ឍន៍ចំនួន ០៤គ្រឿងថ្នាក់មហាសេនាចំនួន ០១គ្រឿង ថ្នាក់ធិបឌិនចំនួន ០២គ្រឿង ថ្នាក់សេនាចំនួន ០៨គ្រឿង និងថ្នាក់អស្សឫទ្ធិចំនួន ១១គ្រឿង)គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌតាមលំដាប់ថ្នាក់ចំនួន ០៨**គ្រឿង**ក្នុងនោះរួមមាន(ថ្នាក់មហាសេរីវឌ្ឍន៍ចំនួន ០១គ្រឿង ថ្នាក់មហាសេនាចំនួន ០៧គ្រឿង) និង **មេដាយការងារ**តាមលំដាប់ថ្នាក់ចំនួន ៨២**គ្រឿង** ក្នុងនោះ(ថ្នាក់មាសចំនួន០៨គ្រឿង ថ្នាក់ប្រាក់ចំនួន២៦គ្រឿង និងថ្នាក់សំរិទ្ធិចំនួន៤៨គ្រឿង) ព្រមទាំងបានផ្តល់ប័ណ្ណសំគាល់ខ្លួនជូនមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសរុបចំនួន ៤៧នាក់/ស្រី ០៦នាក់ ក្នុងនោះ ថ្នាក់ជាតិចំនួន ៣៣នាក់/ស្រី០៥នាក់ និងថ្នាក់ក្រោមជាតិចំនួន ១៤នាក់/ស្រី០១នាក់។

### ៥.៣-ការងារបុគ្គលិករដ្ឋបាលថ្នាក់ជាតិ

គិតត្រឹមខែវិច្ឆិកាឆ្នាំ២០១៨ ស្ថានភាពបច្ចុប្បន្នភាព នៃចំនួនមន្ត្រីរាជការស៊ីវិលតាមមុខតំណែងដែលកំពុងបម្រើការងារនៅគ្រប់អគ្គនាយកដ្ឋាន និងអង្គភាពចំណុះក្រសួងមហាផ្ទៃសរុបចំនួន **៩៨៨រូប/ស្រី២២៦រូប ស្មើនឹង ២២,០៣%** ដែលក្នុងនោះ៖

-មន្ត្រីរាជការស៊ីវិលមានចំនួន**៩៧០រូប/ស្រី ២២៣រូប ស្មើនឹង ២៣,១៤%** ក្នុងនោះរួមមាន (រដ្ឋលេខាធិការចំនួន ០២រូប អនុរដ្ឋលេខាធិការចំនួន ០២រូប/ស្រី០១រូប អគ្គនាយកចំនួន០២រូប  អគ្គនាយករងចំនួន ២៦រូប/ស្រី០២រូប  អគ្គលេខាធិការរងចំនួន ០៥រូប/ស្រី០១រូប ក្រុមប្រឹក្សានីតិកម្មចំនួន ០៩រូប/ស្រី០២រូប លេខាធិការដ្ឋាន-នៃគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គ.ជ.អ.ប ចំនួន ១០រូប/ស្រី ០២រូប អគ្គាធិការចំនួន ០១រូប អគ្គាធិការរងចំនួន ០៥រូប/ស្រី០១រូប ប្រធាននាយកដ្ឋានចំនួន ១៥រូប អនុប្រធាននាយកដ្ឋានចំនួន ១៤៨រូប/ស្រី២៦រូប ប្រធានការិយាល័យចំនួន ៨៥រូប/ស្រី១៨រូប អនុប្រធានការិយាល័យចំនួន ២៣៤រូប/ស្រី៦០រូប និងមន្ត្រីចំនួន ៤២៦រូប/ស្រី១១០រូប។

-មន្ត្រីដែលផ្ទេរភារកិច្ចពីថ្នាក់ក្រោមជាតិមកទីស្តីការក្រសួងចំនួន១៨រូប/ស្រី០៣រូបស្មើនឹង២១,៤២%។

ទន្ទឹមនេះរាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃបានពិនិត្យសម្រេចតែងតាំងមុខតំណែង ប្រគល់ភារកិច្ច ផ្ទេរភារកិច្ច ផ្លាស់ប្តូរកន្លែងធ្វើការមន្ត្រីរាជការសរុបចំនួន ១១រូប/ស្រី០៤រូប។

**៥.៤-ការងារបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១៨ ស្ថានភាពនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេសមានដូចខាងក្រោម ៖

-គណៈអភិបាលរាជធានី ខេត្តសរុបចំនួន១៧៥រូប/ស្រី ២៧រូប ស្មើនឹង១៥,៤២% ក្នុងនោះ (អភិបាលរាជធានី ខេត្តចំនួន **២៥រូប/ស្រី០១រូប** អភិបាលរងរាជធានី ខេត្តចំនួន **១៥០រូប/ស្រី២៦រូប**)

-គណៈអភិបាលក្រុង ស្រុក ខណ្ឌសរុបចំនួន៩០៨រូប/ស្រី១៩២រូបស្មើនឹង២១,១៤% ក្នុងនោះ(អភិបាលក្រុង ស្រុក ខណ្ឌចំនួន **១៩៧រូប/ស្រី ០៧រូប** អភិបាលរងក្រុង ស្រុក ខណ្ឌចំនួន **៧១១រូប/ស្រី ១៨៥រូប**)

-មន្ត្រីស្ថិតក្នុងរចនាសម្ព័ន្ធសាលារាជធានី ខេត្ត ក្រុងស្រុក ខណ្ឌសរុបចំនួន៦.៦១០រូប/ស្រី២.១៥៧រូប ស្មើនឹង ៣២,៦៣% ក្នុងនោះ (រចនាសម្ព័ន្ធសាលារាជធានី ខេត្តចំនួន ២.៨៣០រូប /ស្រី៨៨៤រូប ស្មើនឹង៣១,២៤% រចនាសម្ព័ន្ធសាលាក្រុង ស្រុក ខណ្ឌចំនួន ៣.៧៨០រូប/ស្រី ១.២៧៣រូប ស្មើនឹង ៣៣,៦៨% និងប្រធានច្រកទ្វារព្រំដែនសរុបមានចំនួន **៥៤រូប** ។ ទន្ទឹមនេះរាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃបានពិនិត្យសម្រេចតែងតាំងមុខតំណែង ប្រគល់ភារកិច្ច ផ្ទេរភារកិច្ចអភិបាល អភិបាលរង នៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសរុបចំនួន **១៧រូប/ស្រី០១រូប( ដូចក្នុងឧបសម្ព័ន ១.ក)** និងបានតែងតាំង ប្រគល់ភារកិច្ចជូននាយករដ្ឋបាលនៅក្នុងរចនាសម្ព័ន ចំនួន ០៦រូប (ដូចក្នុងឧបសម្ព័ន ១.ខ)។

**៥.៥-ការងារក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**

គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១៨ ស្ថានភាពសមាជិករបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ទូទាំងប្រទេសមានដូចខាងក្រោម៖

-សមាសភាពក្រុមប្រឹក្សារាជធានី ខេត្តសរុបចំនួន ៣៩៣រូប/ស្រី ៥៦រូប( ស្មើនឹង១៤,២៤%)ក្នុងនោះ (ប្រធានក្រុមប្រឹក្សារាជធានី ខេត្តចំនួន **២៥រូប/ស្រី ០១រូប** សមាជិកក្រុមប្រឹក្សារាជធានី ខេត្តចំនួន **៣៦៨រូប/ស្រី ៥៥រូប**)

-សមាសភាពក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌសរុបចំនួន២៩៣១រូប/ស្រី៤២១រូប(**ស្មើនឹង១៤,៤៣%**)ក្នុងនោះ (ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន **១៩៧រូប/ ស្រី១៧រូប** សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន**២៧៣៤ រូប/ស្រី៤១៧រូប**)។

-សមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់សរុបចំនួន ១១.៥៧២រូប/ស្រី ២.៣៥៤រូប(ស្មើនឹង២០,៣៤%) ក្នុងនោះ(មេឃុំ ១.៤១០រូប/ស្រី១០៦រូប ចៅសង្កាត់ចំនួន ២៣៦រូប/ស្រី ២៤រូប ជំទប់ទី១ចំនួន ១.៤១០រូប/ស្រី២១៧រូប ជំទប់ទី២ចំនួន១.៤១០រូប/**ស្រី២៩៥រូប** ចៅសង្កាត់រងទី១ចំនួន ២៣៦រូប/ស្រី ៦០រូប ចៅសង្កាត់រងទី២ចំនួន ២៣៦រូប/ **ស្រី៤៩រូប** និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន ៦.៦៣៤រូប/ស្រី១.៦០១រូប)។

ទន្ទឹមនេះ ក្រសួងក៏បានផ្លាស់ប្តូរនិងទទួលស្គាល់សមាសភាពក្រុមប្រឹក្សារាជធានីខេត្ត សមាសភាពក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងសមាសភាពក្រុមប្រឹក្សាឃុំសង្កាត់សរុបចំនួន ១៦រូប/ស្រី០៧រូប ក្នុងនោះសមាសភាពក្រុមប្រឹក្សារាជធានី ខេត្តចំនួន ០៣រូប/ស្រី០១(**ដូចក្នុងឧបសម្ព័ន្ធ២.ក**) សមាសភាពក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន ០៥រូប/ស្រី០២រូប (ដូចក្នុង**ឧបសម្ព័ន្ធ២.ខ**)និងសមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន ០៨រូប/ស្រី០៤រូប(**ដូចក្នុងឧបសម្ព័ន្ធ២.គ**)។

**៥.៦-ការងារគ្រប់គ្រងទិន្នន័យមន្ត្រីរាជការស៊ីវិល**

គិតត្រឹមខែវិច្ឆិកាឆ្នាំ២០១៨ ស្ថានភាពបច្ចុប្បន្នភាព នៃចំនួនប្រវត្តិរូបមន្ត្រីរាជការស៊ីវិលទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលបានបញ្ចូលប្រវត្តិរូបក្នុងប្រព័ន្ធទិន្នន័យសរុបចំនួន ៩៥៤០រូប/ ស្រី ២.៦៣៥រូប ក្នុងនោះ៖ មន្ត្រីរាជការស៊ីវិលនៅថ្នាក់ជាតិ ដែលបានបញ្ចូលក្នុងប្រព័ន្ធព័ត៌មានវិទ្យាមានចំនួន ៨៤៥រូប/ស្រី ១៨៧រូប និង មន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិ ដែលបានបញ្ចូលប្រវត្តិរូបក្នុងប្រព័ន្ធព័ត៌មានវិទ្យាបានចំនួន ២៥ រាជធានី ខេត្ត សរុបចំនួន ៨៦.៩៥រូប/ស្រី ២.៤៤៨រូប។

-ជូនដំណឹងដល់អង្គភាពចំណុះក្រសួងមហាផ្ទៃស្តីពីការចាត់មន្ត្រីរាជការ ០១នាក់ ទទួលខុសត្រូវលើការងារបុគ្គលិកជាមន្ត្រីបង្គោល ដើម្បីធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការដែលបម្រើការងារក្នុងរចនាសម្ព័ន្ធគ្រប់អង្គភាពចំណុះទីស្តីការក្រសួងមហាផ្ទៃតាមរយៈការចាត់មន្ត្រីបង្គោល ០១នាក់ នៅតាមការិយាល័យជំនាញនីមួយៗដើម្បីភ្ជាប់ទំនាក់ទំនងផ្តល់ទិន្នន័យ ព្រមទាំងព័ត៌មានសំខាន់ៗ មួយចំនួនរបស់មន្ត្រីរាជការឲ្យបានឆាប់រហ័ស និងទាន់ពេលវេលា ។

**៦-ការងារអភិវឌ្ឍន៍សមត្ថភាព**

**៦.១-ការងារអភិវឌ្ឍន៍សមត្ថភាពក្នុងប្រទេស**

ក្នុងខែវិច្ឆិកាឆ្នាំ២០១៨នេះ អគ្គនាយកដ្ឋានរដ្ឋបាលបានរៀបចំសិក្ខាសាលាមន្ត្រីរដ្ឋបាលជាន់ខ្ពស់ស្តីពី "ភាពជាអ្នកដឹកនាំ និងអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន" ដែលមានសិក្ខាកាមចំនួន **១០៤រូប/ស្រី១៣រូប** នៅសណ្ឋាគារ **សាន់ វេ** រាជធានីភ្នំពេញ ដោយសហការជាមួយ**វិទ្យាស្ថានឡូហ្គូឌី** នៃសាធារណរដ្ឋកូរ៉េ ។

**៦.២-ការងារអភិវឌ្ឍសមត្ថភាពក្រៅប្រទេស និងលិខិតឆ្លងដែន**

ក្នុងខែវិច្ឆិកា ឆ្នាំ២០១៨នេះ ក្រសួងមហាផ្ទៃបានចាត់បញ្ជូនមន្ត្រីរាជកាចំនួន ០៥រូប (ស្រី០១រូប) ឱ្យទៅចូលរួមវេទិកា កម្មវិធីបោះជំរុំ និងវគ្គបណ្តុះបណ្តាលក្រៅប្រទេសដូចខាងក្រោម៖

-បានចាត់បញ្ជូនមន្ត្រីរាជការចំនួន ០១រូប ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "ភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជនបទពិសោធន៍ប្រទេសចិន" នៅទីក្រុងស៊ូចូវ សាធារណរដ្ឋប្រជាមានិតចិន

-បានចាត់បញ្ជូនមន្ត្រីរាជការចំនួន ០៣រូប ដើម្បីចូលរួមក្នុង "វេទិកាកិច្ចសហប្រតិបត្តិការក្នុងចំណោមទីក្រុងទេសចរណ៍តាមបណ្តោយទន្លេមេគង្គ និងទន្លេឡានឆាង" នៅទីក្រុង សេនយ៉ានៃសាធារណរដ្ឋប្រជាមានិតចិន

-បានចាត់បញ្ជូនមន្ត្រីរាជការចំនួន០១រូប(ស្រី០១រូប) និងបានស្នើសុំលិខិតឆ្លងដែនផ្លូវការចំនួន ០១ច្បាប់ ដើម្បីចូលរួមកម្មវិធីការបោះជំរុំយុវជនអាស៊ាន-ចិនលើកទី១១ (11ASEAN-China Youth Camp)។

**៦.៣-ការងារព័ត៌មាន និងផ្សព្វផ្សាយ**

អគ្គនាយកដ្ឋានរដ្ឋបាល បាន និងកំពុងរៀបចំសេចក្តីព្រាងព្រឹត្តិបត្រវិមជ្ឈការ និងវិសហមជ្ឈការលេខ ០៣។ ជាមួយគ្នានេះដែរធ្វើបច្ចុប្បន្នភាពគេហទំព័រអគ្គនាយកដ្ឋានរដ្ឋបាល ក៏បានផ្សព្វផ្សាយ នូវអត្ថបទចំនួន ១៩ និងសេចក្តីជូនដំណឹងចំនួន២នៅក្នុងគេហទំព័ររបស់ខ្លួនរួមមាន៖

- សេចក្តីជូនដំណឹងស្តីពីការជ្រើសរើសបេក្ខភាពសម្រាប់ប្រគល់ពានរង្វាន់សេវាសាធារណៈអង្គការសហប្រជាជាតិឆ្នាំ២០១៩ "The 2019 United Nations Public Service Awards"(UNPSA)
- សេចក្តីជូនដំណឹងស្តីពីការប្រឡងប្រជែងជ្រើសរើសសិស្សមន្ត្រីក្រមការជំនាន់ទី៨ សាលាភូមិន្ទរដ្ឋបាល។

**៧-ការងារគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ**

**៧.១-ការងារគាំទ្របច្ចេកទេស និងអន្តរាគមន៍**

ក្នុងកិច្ចគាំទ្របច្ចេកទេស និងអន្តរាគមន៍ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងមហាផ្ទៃបានដាក់ចេញ នូវគោលការណ៍ណែនាំដល់រដ្ឋបាលរាជធានី ខេត្តដូចខាងក្រោម៖

-រដ្ឋបាលរាជធានីភ្នំពេញ ករណីសំណើសុំជួយអន្តរាគមន៍ទប់ស្កាត់លោកស្រី សៀង ស៊ីពោធិ ពីបទរំលោភលើដីផ្លូវ ដែលមានទីតាំងស្ថិតនៅភូមិដើមគរ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ដើម្បីឱ្យមានផ្លូវចេញចូលដូចដើមវិញ។

-រដ្ឋបាលខេត្តកំពង់ស្ពឺ ករណីសំណើសុំអន្តរាគមន៍ទៅរដ្ឋបាលខេត្ត ដើម្បីចេញលិខិតអនុញ្ញាតចាក់ដីបំពេញដីឡូតិ៍លើផ្ទៃដីស្របច្បាប់ទំហំ ៤ហិកតា ស្ថិតនៅភូមិស្លា ឃុំវល្លិ៍សរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

-រដ្ឋបាលខេត្តកណ្តាល ករណីក្រុមហ៊ុន ING Holding Co., Ltd ស្នើសុំចាត់វិធានការចំពោះជនខិលខូចដែលបំពានដីក្រុមហ៊ុនទំហំ ៧៤.១៥៣ម៉ែត្រការ៉េ ក្នុងតំបន់អភិវឌ្ឍន៍ទីក្រុងរណបបឹងទំពុន និងបឹងជើងឯក។

-រដ្ឋបាលខេត្តឧត្តរមានជ័យ ករណីសំណើសុំគោលការណ៍អនុញ្ញាតឱ្យរដ្ឋបាលខេត្តសម្របសម្រួលរៀបចំកម្មវិធីសហការជាមួយខេត្តសុរិន្ទ ដើម្បីរៀបចំកម្មវិធី "ជិះកង់១ថ្ងៃកម្សាន្ត២ប្រទេស"។

-ក្រុមហ៊ុន សុផាន់នីធីប៊ីឌីវេឡុបមេន ករណីសំណើសុំដាក់ដំណើរការអាជីវកម្មឆ្នោតរបស់ក្រុមហ៊ុនសុផាន់នីធីប៊ីឌីវេឡុបមេន នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តទូទាំងព្រះរាជាណាចក្រកម្ពុជា។

-ករណីលោកបណ្ឌិត អ៊ី សាមុអូកាដា សាស្ត្រាចារ្យ នៃសាកលវិទ្យាល័យណាហ្គោយ៉ា ស្នើសុំធ្វើការស្ទង់មតិអំពី"ទស្សនៈរបស់ប្រជាពលរដ្ឋលើរាជរដ្ឋាភិបាលកម្ពុជា" នៅខេត្តសៀមរាប។

-ពិនិត្យ និងលើកយោបល់ ករណីឈ្មោះ ជា គួង ប្រធានក្រុមហ៊ុនគីម ជ្រាស្នើសុំជួយអន្តរាគមន៍ទៅអភិបាលខេត្តរតនគិរីដើម្បីផ្អាកការអនុវត្តដីកាលេខ ០២៩/១៨ដក. ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៨ របស់រដ្ឋបាលខេត្តរតនគិរីជាបណ្តោះអាសន្ន។

-បានរៀបចំប្រកាសស្តីពីការបង្កើត និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវនិមិត្តសញ្ញាខេត្តព្រៃវែង។

-បានដាក់ចេញសេចក្តីជូនដំណឹងលេខ ១៩៦១ សជណ ស្តីពីការរៀបចំសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០១៨ និងលើកដៅការងារឆ្នាំ២០១៩ របស់រដ្ឋបាលរាជធានី ខេត្ត។

**៧.២-ការងារបង្កើត កែសម្រួល និងកំណត់ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ**

បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជាមានរាជធានីចំនួន ០១ ខេត្ត ២៤ ខណ្ឌ ១២ ក្រុង ២៦ ស្រុក ១៥៩ សង្កាត់២៣៦ ឃុំ១.៤១០ និងភូមិចំនួន ១.៤៣៨៣ ។ ទន្ទឹមនោះក្រសួងមហាផ្ទៃ ក៏បានធ្វើលិខិតណែនាំទៅរាជធានី ខេត្តដូចខាងក្រោម៖

-រដ្ឋបាលខេត្តកណ្តាល ករណីស្នើសុំកាត់ផ្ទេរឃុំចំនួន ០៤ស្ថិតក្នុងស្រុកស្អាងព្រមទាំងផ្ទៃដីមួយផ្នែកទៀតនៃស្រុកកណ្តាលស្ទឹងមកបញ្ចូលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុងតាខ្មៅ ខេត្តកណ្តាល។

-រដ្ឋបាលខេត្តព្រះសីហនុ ករណីស្នើសុំបង្កើតក្រុងកោះរុង ដោយបំបែកចេញពីក្រុងព្រះសីហនុរួមជាមួយសំណើសុំកាត់ឃុំចំនួនពីរគឺ ឃុំរាម ឃុំបិតត្រាំងពីស្រុកព្រៃនប់ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុងព្រះសីហនុ និងកែសម្រួលព្រំប្រទល់រដ្ឋបាលឃុំអូរត្រេះ ស្រុកស្ទឹងហាវ និងសង្កាត់លេខ១ ក្រុងព្រះសីហនុ ដោយកាត់យកផ្ទៃដីមួយផ្នែកនៃឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុមកបញ្ចូលក្នុងសង្កាត់លេខ១ ក្រុងព្រះសីហនុ។

-រដ្ឋបាលខេត្តកំពត ករណីស្នើសុំកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងក្រុងកំពត និងស្រុកទឹកឈូ ក្នុងភូមិសាស្ត្រខេត្តកំពត។

-រដ្ឋបាលខេត្តកំពង់ធំ ករណីស្នើសុំបំបែកស្រុកបារាយណ៍ជាពីរ។

-រដ្ឋបាលខេត្តព្រៃវែង ករណីស្នើសុំកាត់ឃុំតាកោពីស្រុកពោធិ៍រៀងបញ្ចូលក្នុងរដ្ឋបាលដែនដីក្រុងព្រៃវែង។

-រដ្ឋបាលខេត្តស្ទឹងត្រែង ករណីស្នើសុំបង្កើតស្រុកបូរីអូរស្វាយសែនជ័យ។

-រដ្ឋបាលខេត្តព្រះវិហារ ករណីស្នើសុំបង្កើតស្រុកថ្មីចំនួន ០១ និងកំណត់ព្រំប្រទល់រដ្ឋបាលរវាងឃុំ និង ឃុំ ស្រុក និងស្រុក។

**៧.៣-ការងារផ្តល់គោរម្យងារ គ្រឿងឥស្សរិយយស និងមេដាយស្ថាបនាជាតិ**

ក្រសួងមហាផ្ទៃបានស្នើទៅរាជរដ្ឋាភិបាលកម្ពុជា ករណីផ្តល់នូវគោរម្យងារជាឧញ៉ាចំនួន ០៣រូប មេដាយព្រះរាជាណាចក្រកម្ពុជាចំនួន ៥៣គ្រឿង (ថ្នាក់មហាសេរីវឌ្ឍន៍ចំនួន ០៦គ្រឿង ថ្នាក់មហាសេនាចំនួន ១៤គ្រឿង ថ្នាក់ធិបឌិន្ទចំនួន ០៩គ្រឿង ថ្នាក់សេនាចំនួន ១៣គ្រឿង និងថ្នាក់អស្សឫទ្ធិចំនួន ១១គ្រឿង) មេដាយសុវត្ថារាចំនួន ០៣គ្រឿង (ថ្នាក់មហាសេរីវឌ្ឍន៍ចំនួន ០៣គ្រឿង) មេដាយមុនីសារាភ័ណ្ឌចំនួន ៥៥គ្រឿង (ថ្នាក់មហាសេរីវឌ្ឍន៍ចំនួន ០៩គ្រឿង ថ្នាក់ធិបឌិន្ទចំនួន ០៤គ្រឿង ថ្នាក់សេនាចំនួន ១៣គ្រឿង (ថ្នាក់មហាសេរីវឌ្ឍន៍ចំនួន ០៣គ្រឿង) និងថ្នាក់អស្សឫទ្ធិចំនួន ២៩គ្រឿង) មេដាយសម្តេចមហាក្សត្រីយានីកុសុមៈនារីរ័ត្នចំនួន ០៣គ្រឿង មេដាយសេនាជ័យសិទ្ធចំនួន ០៤គ្រឿង មេដាយស្ថាបនាជាតិ ចំនួន ៥៣គ្រឿង (មេដាយមាសស្ថាបនាជាតិចំនួន ៤៧គ្រឿង និងមេដាយប្រាក់ស្ថាបនាជាតិចំនួន ០៦គ្រឿង) មេដាយការងារចំនួន ២៤គ្រឿង (មេដាយមាសការងារចំនួន ១៥គ្រឿងនិងមេដាយប្រាក់ការងារចំនួន ០៩គ្រឿង) ដើម្បីផ្តល់ជូនសប្បុរសជន ដែលបានជួយកសាងសមិទ្ធផលជាច្រើននៅខេត្តបាត់ដំបង ព្រៃវែង ឧត្តរមានជ័យ សៀមរាប និងរាជធានីភ្នំពេញដោយចំណាយអស់ថវិកាសរុបចំនួន ៥.០៦៧.៧២៥ដុល្លារ (ប្រាំលានហុកសិបប្រាំពីរពាន់ប្រាំបីរយម្ភៃប្រាំដុល្លារសហរដ្ឋអាមេរិក)(ដូចក្នុងឧបសម្ព័ន្ធ ៣)។

## ៧.៤-ការងារសម្របសម្រួល និងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងគម្រោងនានា

### ៧.៤.១-កម្មវិធីគាំទ្រដោយអង្គការ UNICEF

-ចូលរួមទស្សនកិច្ចសិក្សាអន្តរក្រសួងដើម្បីកំណត់វឌ្ឍនភាព ឧបសគ្គ និងដំណោះស្រាយនៃការអនុវត្តកម្មវិធីរបស់អង្គការយូនីសេហ្វក្នុងការផ្តល់ឧត្តមប្រយោជន៍ដល់កុមារ

-បានលើកសំណើសុំគោលការណ៍អនុញ្ញាតពីសម្តេចក្រឡាហោមក្នុងការអនុវត្តក្របខណ្ឌសហប្រតិបត្តិការរវាងអង្គការទស្សនៈពិភពលោកអន្តរជាតិកម្ពុជា និងអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ដើម្បីរៀបចំសៀវភៅណែនាំស្តីពីកិច្ចការពារកុមារសម្រាប់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

-ប្រជុំពិនិត្យសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នាស្តីពីគំនិតផ្តួចផ្តើមរួមគ្នាធ្វើឱ្យប្រសើរឡើងនូវតួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ រវាងអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ និងអង្គការទស្សនៈពិភពលោកអន្តរជាតិកម្ពុជា

-ចុះតាមដានត្រួតពិនិត្យ និងគាំទ្របច្ចេកទេសដល់រដ្ឋបាលខេត្តសៀមរាប (ស្រុកស្រីស្នំ) និងរាជធានីភ្នំពេញ (ខណ្ឌជ្រោយចង្វារ)ក្នុងវគ្គបណ្តុះបណ្តាលសៀវភៅណែនាំស្តីពីការអនុវត្តសកម្មភាពសេវាសង្គមឃុំ សង្កាត់ សរុបចំនួន២វគ្គ

-ចុះត្រួតពិនិត្យរួមគ្នាលើការអនុវត្តផែនការសកម្មភាពកម្មវិធីប្រចាំប្រទេស (CPAP-JMV) និងចុះតាមខេត្តគោលដៅរបស់អង្គការយូនីសេហ្វ រួមមានខេត្តបាត់ដំបង ខេត្តព្រៃវែង ខេត្តកំពង់ចាម និងខេត្តក្រចេះ

-បានចូលរួមត្រួតពិនិត្យផែនការសកម្មភាពឆ្នាំ ២០១៦-២០១៨ រវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការ UNICEF នៅខេត្តបាត់ដំបង និងខេត្តកំពង់ចាម។

### ៧.៤.២-កម្មវិធីគាំទ្រដោយអង្គការតម្លាភាពកម្ពុជា TIC

-ជំរុញ និងលើកទឹកចិត្តដល់ប្រជាពលរដ្ឋនៅស្រុកថ្មពួក និងឃុំបន្ទាយឆ្មារ ឱ្យចូលរួមទាំងអស់គ្នាក្នុងដំណើរការអភិវឌ្ឍន៍របស់រដ្ឋបាលស្រុក ឃុំ។

### ៧.៤.៣-កម្មវិធីគាំទ្រដោយវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល GGGI

ប្រជុំជាមួយក្រសួងបរិស្ថាន ដើម្បីពិនិត្យ និងកែសម្រួលសេចក្តីព្រាងផែនការយុទ្ធសាស្ត្រទីក្រុងនិរន្តភាពឆ្នាំ ២០១៨។

### ៧.៤.៤-គម្រោងសាងសង់អាគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់ DCOCP

-បានពិនិត្យ និងកែសម្រួលចំណុចមួយចំនួននៃប្លង់អគាររដ្ឋបាល និងអគារសាលប្រជុំសាលាក្រុង ស្រុក និងប្លង់អគាររដ្ឋបាលឃុំ សង្កាត់

-រៀបចំទ្រឹស្តីបច្ចេកទេសសម្រាប់ការសាងសង់អគាររដ្ឋបាលក្រុង ស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់

-បានរៀបចំរបាយការណ៍នៃការចាប់ផ្តើមអនុវត្តគម្រោង

-ធ្វើរបាយការណ៍នៃការសិក្សាអង្កេតវាស់វែង ទីតាំងសម្រាប់សាងសង់របស់ស្រុក និងឃុំ សង្កាត់គោលដៅ នៅខេត្តកណ្តាល ព្រៃវែង កំពង់ចាម និងខេត្តបាត់ដំបង

-ចុះពិនិត្យទីតាំងសម្រាប់សាងសង់របស់ស្រុក និងឃុំ សង្កាត់គោលដៅ ដំណាក់កាលទី២។

## ៧.៥-ការងារគម្រោងមូលនិធិ និងការគាំទ្រក្រុង ស្រុក ឃុំ សង្កាត់

### ៧.៥.១-គម្រោងមូលនិធិក្រុង ស្រុក

គិតត្រឹមខែវិច្ឆិកាឆ្នាំ២០១៨នេះ សំណើគម្រោងមូលនិធិក្រុង ស្រុកឆ្នាំ២០១៨ មានចំនួន **៤៧៣** គម្រោងដែលក្នុងនោះ៖ គម្រោងកំពុងបន្តការសិក្សាចំនួន**៧៣**គម្រោង(ស្មើនឹង១៥%) គម្រោងមិនទាន់សិក្សាចំនួន៤៩ គម្រោង (ស្មើនឹង១០%) និងគម្រោងដែលបានបញ្ចប់ការសិក្សាចំនួន**៣៥១**គម្រោង (ស្មើនឹង៧៥%)។ជាមួយគ្នានោះសំណើគម្រោងមូលនិធិក្រុងស្រុក ឆ្នាំ២០១៧មានចំនួន **២៧៥**គម្រោងក្នុងនោះរួមមាន៖ គម្រោងអនុវត្តលើសពី ៥០% ចំនួន **០១**គម្រោង (ស្មើនឹង ០.៥%) គម្រោងមិនទាន់បានអនុវត្ត **០១**គម្រោង (ស្មើនឹង ០.៥%)និងគម្រោងដែលបានបញ្ចប់ការសាងសង់ ១០០% ចំនួន **២៧៣**គម្រោង (ស្មើនឹង ៩៩%)(**ដូចក្នុងឧបសម្ព័ន្ធ៤.ក**)។

#### ៧.៥.២-គម្រោងមូលនិធិឃុំ សង្កាត់

សំណើគម្រោងមូលនិធិឃុំសង្កាត់ឆ្នាំ២០១៨មានចំនួន ១៧៧៨គម្រោង ក្នុងនោះគម្រោងដែលកំពុងសិក្សាចំនួន ២៩៤គម្រោង (ស្មើនឹង១៦%) គម្រោងដែលមិនទាន់ចាប់ផ្តើមសិក្សាចំនួន ៥២គម្រោង (ស្មើនឹង៣%) គម្រោងដែលបានដេញថ្លៃរួចចំនួន ៩៩៣គម្រោង(ស្មើនឹង៥៦%)និងគម្រោងដែលបានបញ្ចប់ការសិក្សាចំនួន៤៣៩គម្រោង(ស្មើនឹង២៥%)។ ចំពោះការអនុវត្តកិច្ចសន្យាសាងសង់របស់គម្រោងរដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០១៨ សរុបចំនួន ៨២៤ កិច្ចសន្យា ក្នុងនោះរួមមានៈ ការអនុវត្តកិច្ចសន្យាបានលើសពី៥០%ចំនួន ១២៧(ស្មើនឹង១៦%)ការអនុវត្តកិច្ចសន្យាបានតិចជាង៥០%ចំនួន ១២១(ស្មើនឹង១៥%) ការបញ្ចប់កិច្ចសន្យាសាងសង់១០០%ចំនួន ២៨៤(ស្មើនឹង៣៤%) កិច្ចសន្យាមិនទាន់បានអនុវត្តចំនួន២៩២ (ស្មើនឹង៣៤%)(**ដូចក្នុងឧបសម្ព័ន្ធ៤.ខ**)។

ទន្ទឹមនេះការអនុវត្តកិច្ចសន្យាសាងសង់របស់គម្រោងរដ្ឋបាលឃុំសង្កាត់ឆ្នាំ២០១៧សរុបចំនួន ១៦៤២កិច្ចសន្យា ក្នុងនោះរួមមានៈការអនុវត្តកិច្ចសន្យាបានលើសពី៥០%ចំនួន ៦០(ស្មើនឹង៣%) ការអនុវត្តកិច្ចសន្យាបានតិចជាង៥០%ចំនួន ១២ (ស្មើនឹង១%) ការបញ្ចប់កិច្ចសន្យាសាងសង់១០០%ចំនួន ១៥២៤(ស្មើនឹង៩៣%) និងកិច្ចសន្យាមិនទាន់បានអនុវត្ត ចំនួន ៤២ (ស្មើនឹង៣%) ។

### ៧.៦-ការផ្តល់សេវា និងការដោះស្រាយវិវាទនៅមូលដ្ឋាន

#### ៧.៦.១-ការផ្ទេរមុខងារ និងធនធាន

-បានសហការជាមួយក្រុមការងាររបស់លេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីចុះសិក្សារៀបចំចងក្រងករណីសិក្សាដែលមានលក្ខណៈជាមេរៀនបទពិសោធន៍ល្អៗ នៃការអនុវត្តមុខងារជាអាណត្តិទូទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅខេត្តកំពត និងខេត្តកំពង់ឆ្នាំង

-បានចូលរួមកិច្ចប្រជុំពិភាក្សាអន្តរក្រសួងស្តីពីការគ្រប់គ្រង និងកែច្នៃសំណល់រឹង និងការ កែសម្រួលលើការគ្រប់គ្រងមូលនិធិបរិស្ថាន និងសង្គម នៅទីស្តីការក្រសួងបរិស្ថាន និងការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលក្រុងព្រះសីហនុ ខេត្តព្រះសីហនុ នៅលេខាធិការដ្ឋាន គ.ជ.អ.ប

-បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយប្រកាសអន្តរក្រសួងស្តីពីការកំណត់កម្រៃអតិបរមានៃសេវាគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្រសួងមហាផ្ទៃ។

#### ៧.៦.២-ការផ្តល់សេវាតាមរយៈយន្តការច្រកចេញចូលតែមួយ

#### ក.ការផ្តល់សេវាតាមរយៈអង្គភាពច្រកចេញចូលតែមួយ

ក្នុងខែវិច្ឆិកាឆ្នាំ២០១៨នេះ អង្គភាពច្រកចេញចូលតែមួយទាំង ២៥រាជធានី ខេត្ត បានផ្តល់សេវារដ្ឋបាលសរុបចំនួន ២៧,៣៤១សេវា ក្នុងនោះបើប្រៀបធៀបចំនួនសេវាដែលបានផ្តល់នៅក្នុងចំណោមវិស័យទាំង១៤ ឃើញថា វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានផ្តល់សេវាបានច្រើនជាងគេគឺចំនួន ១១,០២៤សេវា (ស្មើនឹង៤០,៣២% នៃសេវាសរុប) បន្ទាប់មកវិស័យការងាររដ្ឋបាល ចំនួន ១០,៨៤៣សេវា (ស្មើនឹង៣៩,៦៦%) ចំណែកវិស័យបរិស្ថានបានតិចជាងគេគឺចំនួន ០៩សេវា(ស្មើនឹង ០,០៣%)(**ដូចក្នុងឧបសម្ព័ន៥**)។ ជាមួយគ្នានេះដែរ អង្គភាពច្រកចេញចូលតែមួយចំនួនទាំង២៥រាជធានី ខេត្ត ទទួលបានចំណូលសរុបចំនួន ១០២៧,៧៦០,១០៩រៀល (ស្មើនឹង២៥៦,៩៤០ ដុល្លារអាមេរិក) ក្នុងនោះប្រៀបធៀបចំណូលដែលទទួលបានក្នុងចំណោមវិស័យទាំង១៤ឃើញថា វិស័យរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ទទួលបានចំណូលខ្ពស់ជាងគេគឺចំនួន ២៦៧,៦៦៨,៧០៩រៀល (ស្មើនឹង២៦,០៤%) បន្ទាប់មកវិស័យពាក់ព័ន្ធនឹង ការងាររដ្ឋបាល ទទួលបានចំណូលចំនួន ២៥០,៦១៥,៥០០រៀល និងវិស័យពាណិជ្ជកម្មទទួលបានចំណូលតិចជាងគេគឺចំនួន២,៧៩៥,០០រៀល(ស្មើនឹង០,២៧%) (**ដូចក្នុងឧបសម្ព័ន ៦**)។

#### ខ.ការផ្តល់សេវាតាមរយៈការិយាល័យច្រកចេញចូលតែមួយ

គិតត្រឹមថ្ងៃទី២០ខែវិច្ឆិកាឆ្នាំ២០១៨ ការិយាល័យច្រកចេញចូលតែមួយទាំង៥២គោលដៅបានផ្តល់សេវារដ្ឋបាលសរុបចំនួន ១២៨,៨៨៥សេវា ក្នុងនោះបើប្រៀបធៀបចំនួនសេវាដែលបានផ្តល់នៅក្នុងចំណោមវិស័យទាំង

១៤ ឃើញថា វិស័យនីត្យានុកូលកម្ម បានផ្តល់សេវាបានច្រើនជាងគេគឺចំនួន ៩០,២៣៣សេវា (ស្មើនឹង ៧១,៥៧% នៃសេវាសរុប)បន្ទាប់មក វិស័យអត្រានុកូលដ្ឋានចំនួន២៥,៣២៣សេវា(ស្មើនឹង១៩,៧៨%) ចំណែកវិស័យការងាររដ្ឋបាល បានផ្តល់សេវាបានតិចជាងគេគឺ១៦សេវា(ស្មើនឹង០,០១%នៃសេវាសរុប)(ដូចក្នុងឧបសម្ព័ន ៧)។

រយៈពេលដូចគ្នានេះដែរ ការិយាល័យច្រកចេញចូលតែមួយទាំង៥២គោលដៅ ទទួលបានចំណូលសរុបចំនួន១.២៤៨.៤៨៣.៨៤១រៀល(ស្មើនឹង៣១២,១២០,៩៦ដុល្លារអាមេរិក)ដែលក្នុងនោះបើប្រៀបធៀបចំណូល ដែលទទួលបាននៅក្នុងចំណោមវិស័យទាំង១៤ ឃើញថា វិស័យសុរិយាជីមានចំណូលខ្ពស់ជាងគេគឺចំនួន ៧៣២.៧៦០.០០០រៀល(ស្មើនឹង៥៨,៦៩%នៃសេវាសរុប)បន្ទាប់មកវិស័យសំណង់ចំនួន ១៥៤.២៤៩.២០០រៀល និងវិស័យឧស្សាហកម្មនិងសប្បកម្មមានចំណូលតិចជាងគេគឺ៩៥៥.០០០រៀល(ដូចក្នុងឧបសម្ព័ន៨)។ចំណែកវិស័យអត្រានុកូលដ្ឋានបានផ្តល់សេវាជូនប្រជាពលរដ្ឋតែមិនបានប្រមូលចំណូលទេ។

### ៧.៦.៣-ការដោះស្រាយវិវាទរដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

គិតត្រឹមថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨ ការិយាល័យប្រជាពលរដ្ឋទាំង ៥២គោលដៅ បានទទួលបណ្តឹង សំណូមពរ ការទិតៀន ការសរសើរ និងការសាកសួរព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋដែលពាក់ព័ន្ធ និងមិនពាក់ព័ន្ធជាមួយនឹងការិយាល័យច្រកចេញចូលតែមួយសរុបចំនួន ៧០៤ករណី ដែលក្នុងនោះបណ្តឹងក្នុងសមត្ថកិច្ចចំនួន ០១ករណី បញ្ចប់ការដោះស្រាយ ០១ករណី បណ្តឹងក្រៅសមត្ថកិច្ចចំនួន ៣១ករណី សំណូមពរ និងការទិតៀនចំនួន ៤៣ករណី ការសរសើរចំនួន ៣៣ករណី ការសាកសួរព័ត៌មានផ្សេងៗចំនួន ៥៩៦ករណី(ក្នុងសមត្ថកិច្ច ៥៨៨ករណីនិងក្រៅសមត្ថកិច្ច ៨ករណី)(ដូចក្នុងឧបសម្ព័ន ៩)។ ចំពោះលទ្ធផលនៃការដោះស្រាយបណ្តឹងតវ៉ា ដោយក្រុមការងារគណនេយ្យភាពរាជធានី ខេត្តក្នុងខែវិច្ឆិកានេះពុំមានអ្វីប្រែប្រួលនោះទេ។

ទន្ទឹមនេះ អគ្គនាយកដ្ឋានរដ្ឋបាលក៏បានសហការសម្របសម្រួល និងគាំទ្រលើដំណើរការនៃការដោះស្រាយវិវាទរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដូចខាងក្រោម៖

-បានរៀបចំសំណើសុំគោលការណ៍រៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើសៀវភៅណែនាំស្តីពីបែបបទ និងនីតិវិធីនៃការទទួល និងការសម្រុះសម្រួលដោះស្រាយបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋ

-បានទំនាក់ទំនងទៅប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តមួយចំនួនដើម្បីធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះប្រធាន និងអនុប្រធានផ្នែក

-បានទំនាក់ទំនងទៅរដ្ឋបាលខេត្តប៉ៃលិនក្នុងការបោះឆ្នោតជ្រើសរើសអនុប្រធានការិយាល័យប្រជាពលរដ្ឋខេត្តប៉ៃលិន។

## ៨-ការងារសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពនានា

ក្នុងខែវិច្ឆិកា ឆ្នាំ២០១៨នេះ ក្រសួងមហាផ្ទៃបានធ្វើលិខិតជម្រាបទៅក្រសួង ស្ថាប័នដូចខាងក្រោម៖

-**ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ** ករណីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ស្នើសុំចាត់បញ្ជូនតំណាង ០១រូប ចូលរួមជាសមាជិកលេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ច។

-**ក្រសួងផែនការ** ករណីក្រសួងផែនការស្នើសុំចាត់មន្ត្រី ០១រូប ចូលរួមធ្វើជាសមាជិកនៃគណៈកម្មការបច្ចេកទេសអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩។

-**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ករណីស្នើសុំចាត់តំណាងក្រសួងមហាផ្ទៃចូលរួមក្នុងសមាសភាពគណៈកម្មការចំពោះកិច្ច ដើម្បីពិនិត្យ និងដោះស្រាយផលប៉ះពាល់ពីការបញ្ឈប់សិទ្ធិធ្វើអាជីវកម្មភាស៊ីផ្សារចាស់ស្ទឹងត្រែងមុនចប់អាណត្តិកិច្ចសន្យារបស់អ្នកវិនិយោគ សា លាង។

- **អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ** ករណីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ៖

- ស្នើសុំព័ត៌មានស្តីពីវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការកម្ពុជា-ឡាវ
- ស្នើសុំព័ត៌មានស្តីពីវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការកម្ពុជា-វៀតណាម
- ស្នើសុំផ្តល់មតិយោបល់ស្តីពីកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងនេប៉ាល់
- ស្នើសុំផ្តល់របាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តកំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មការចម្រុះសម្រាប់
- កិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ឥណ្ឌូនេស៊ីលើកទី៣
- ស្នើសុំរបាយការណ៍ស្តីពីការអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការកម្ពុជា-ស្វីស។

## ៩.ការងារតាមវិស័យផ្សេងៗ

### ៩.១-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន

បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជាមានច្រកទ្វារព្រំដែនសរុបចំនួន ៨២ច្រក រួមមានច្រកទ្វារកំពង់ផែអន្តរជាតិចំនួន ០៣ច្រក ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិចំនួន ០៣ច្រក ច្រកទ្វារព្រំដែនអន្តរជាតិចំនួន ២៣ច្រក ច្រកទ្វារព្រំដែនទ្វេភាគីចំនួន ១៤ច្រក ច្រកទ្វារតំបន់ព្រំដែនចំនួន ២៩ច្រក និងច្រកទ្វារកំពង់ផែសមុទ្រចំនួន ១០ច្រក។

គិតចាប់ពីថ្ងៃទី២៦ ខែតុលា ដល់ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៨ អគ្គនាយកដ្ឋានរដ្ឋបាលបានផ្តល់ប័ណ្ណព្រំដែនជូនរដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃបានចំនួន ១២.០០០ក្បាល (ក្នុងនោះខេត្តបាត់ដំបងចំនួន ៧.០០០ក្បាល និងខេត្តបន្ទាយមានជ័យចំនួន ៥.០០០ក្បាល)។ ជាមួយគ្នានេះដែរ រដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃបានផ្តល់ប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋចំនួន ៨.៦៦៥ក្បាល និង រដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ឡាវបានផ្តល់ប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋចំនួន ០១ក្បាល ដើម្បីប្រើប្រាស់ឆ្លងកាត់ព្រំដែន(**ដូចក្នុងឧបសម្ព័ន១០**)។ទន្ទឹមនោះក៏បានធ្វើលិខិតទៅរដ្ឋបាលខេត្តកំពត ករណីភាគីវៀតណាមសាងសង់ផ្លូវមួយខ្សែតាមបណ្តោយព្រំដែន រវាងខេត្តកំពត និងខេត្តគៀនយ៉ាង(វៀតណាម)ពីបង្គោលព្រំដែនលេខ២៨៧ ដល់បង្គោលលេខ២៩៥ និងបន្តពីបង្គោលលេខ៣០១ដល់បង្គោលលេខ៣១៤។

### ៩.២-ការងារចងសម្ព័ន្ធមេត្រីភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ដើម្បីបង្កើនទំនាក់ទំនង ចងសម្ព័ន្ធមេត្រីភាពជាមិត្តភាព និងសហប្រតិបត្តិការជាមួយបណ្តាប្រទេសនានាជាមិត្ត ក្រសួងមហាផ្ទៃបានអនុញ្ញាតឱ្យ៖

-រដ្ឋបាលខេត្តសៀមរាប ដឹកនាំប្រតិភូខេត្តទៅចូលរួមវេទិកាក្រុងសានយ៉ាឆ្នាំ២០១៨ ស្តីពីកិច្ចសហប្រតិបត្តិការនៃបណ្តាក្រុងទេសចរណ៍មេគង្គ-ឡានឆាងនៅក្រុងសានយ៉ា ខេត្តហៃណាននៃសាធារណរដ្ឋប្រជាមានិតចិន។

-រដ្ឋបាលខេត្តឧត្តរមានជ័យ សម្របសម្រួលរៀបចំកម្មវិធីសហការជាមួយខេត្តសុរិន្ទ ដើម្បីរៀបចំកម្មវិធី "ជិះកង់១ថ្ងៃកម្សាន្ត២ប្រទេស"។

### ៩.៣-ការងារវិនិយោគ អភិវឌ្ឍន៍ និងអន្តរវិស័យ

ក្នុងខែវិច្ឆិកាឆ្នាំ២០១៨នេះ អគ្គនាយកដ្ឋានរដ្ឋបាល បានពិនិត្យនិងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងសុំផ្តល់អនុលោមភាពគម្រោងអភិវឌ្ឍឆ្នាំ២០១៨ចំនួន ៣១គម្រោង មានទឹកប្រាក់សរុបចំនួន ៤៤.៩៦៨.០៣៧.០០០រៀល (សែសិបបួនប៊ីលានប្រាំបួនរយហុកសិបប្រាំបីលានសាមសិបប្រាំពីរពាន់រៀលគត់)របស់រដ្ឋបាលរាជធានី ខេត្ត ចំនួន ៥រួមមាន៖ រាជធានីភ្នំពេញ(៣គម្រោង) ខេត្តកំពង់ឆ្នាំង(២គម្រោង) ខេត្តប៉ៃលិន(២០គម្រោង) ខេត្តកំពត (៣គម្រោង) និងខេត្តព្រះសីហនុ(៣គម្រោង)(**ដូចក្នុងឧបសម្ព័ន ១១**)។

-ថ្នាក់ដឹកនាំក្រសួងបានសម្រេចផ្តល់អនុលោមភាពលើគម្រោងអភិវឌ្ឍឆ្នាំ២០១៨ មានចំនួន ៤គម្រោង មានទឹកប្រាក់សរុបចំនួន ៦.៣៦៤.៧៩០.០០០ រៀល (ប្រាំមួយប៊ីលានបីរយហុកសិបបួនលានប្រាំពីររយកៅសិបពាន់រៀលគត់)របស់រដ្ឋបាលខេត្តចំនួន ២ រួមមាន: ខេត្តបាត់ដំបង(១គម្រោង)និងខេត្តតាកែវ(៣គម្រោង) (**ដូចក្នុងឧបសម្ព័ន ១២**)។

-បានធ្វើលិខិតក្នុងនាមក្រសួងមហាផ្ទៃគោរពជូនសម្តេចតេជោនាយករដ្ឋមន្ត្រី ករណីក្រុមហ៊ុនភ្នំពេញលែនឌីវេឡុបមែន ឯ.ក ស្នើសុំវិនិយោគអភិវឌ្ឍន៍ និងសុំជាកម្មសិទ្ធិ ៦០% លើតំបន់បឹងកង្កែប ស្ថិតនៅភូមិអុង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

### ៩.៤-ការងារកិច្ចការសមាគម និងគណបក្សនយោបាយ

#### ៩.៤.១-ការងារកិច្ចការសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

បច្ចុប្បន្ន សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះឈ្មោះក្នុងបញ្ជីនៅក្រសួងមហាផ្ទៃចំនួន ៥.៥០៧ ក្នុងនោះ(សមាគមចំនួន ២.២៨៦ អង្គការមិនមែនរដ្ឋាភិបាលចំនួន ៣.២២១)។ដោយឡែកក្នុងខែវិច្ឆិកា ឆ្នាំ២០១៨ ក្រសួងមហាផ្ទៃបានសម្រេចចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងបញ្ជីមានចំនួន ១៨ ក្នុងនោះ សមាគម

ចំនួន៩ អង្គការមិនមែនរដ្ឋាភិបាលចំនួន ៨ និងសហគមន៍ជនជាតិដើមភាគតិចចំនួន ១។ ជាមួយគ្នានេះដែរ ក៏បានបញ្ចូលទិន្នន័យស្កែនសំណុំឯកសារពាក់ព័ន្ធរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ៧១ច្បាប់ ក្នុងនោះសមាគម ៤១ អង្គការមិនមែនរដ្ឋាភិបាល ៣០។ ក្រៅពីនេះក៏បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យសម្រេចពាក់ព័ន្ធនឹងការងារនានាដូចជា ការសុំចុះ ឈ្មោះក្នុងបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ការសុំទទួលស្គាល់ប្រធាន និងសមាសភាពថ្មី នៃរចនាសម្ព័នការសុំធ្វើវិសោធនកម្មលក្ខន្តិកៈ ការសុំប្តូរអាសយដ្ឋាននៃទីស្នាក់ការកណ្តាល ការសុំបើកទីស្នាក់ការសាខា ការសុំប្តូរឈ្មោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ការលុបឈ្មោះ និងការផ្អាកសកម្មភាពបណ្តោះអាសន្ន ចំពោះសមាគមអង្គការមិនមែនរដ្ឋាភិបាលតាមបទប្បញ្ញត្តិ ដែលកំណត់ដោយច្បាប់ ។ លើសពីនេះ ក្រសួងមហាផ្ទៃក៏បានដាក់ចេញ នូវសេចក្តីណែនាំស្តីពីកិច្ចសហប្រតិបត្តិការ រវាងរាជរដ្ឋាភិបាលជាមួយសមាគម អង្គការមិនមែនរដ្ឋាភិបាលព្រមទាំងសហគមន៍នានានៅមូលដ្ឋាន និងបានណែនាំដល់រដ្ឋបាលរាជធានីខេត្តស្តីពីការធ្វើសកម្មភាពរបស់សមាគម អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍នានានៅមូលដ្ឋាន ដោយពុំចាំបាច់ជូនដំណឹងដល់អាជ្ញាធរមូលដ្ឋាន៣ថ្ងៃមុននោះឡើយ ។ ជាមួយគ្នានេះដែរអគ្គនាយកដ្ឋានរដ្ឋបាល ក៏បានរៀបចំកិច្ចប្រជុំជាមួយអង្គការ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា " CCC "ដើម្បីរៀបចំឯកសារពាក់ព័ន្ធនឹងការធ្វើដំណើរសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលបានតម្កល់សំណុំឯកសារនិងចុះបញ្ជីនៅក្រសួងមហាផ្ទៃ។

**៩.៤.២-ការងារគណបក្សនយោបាយ**

បច្ចុប្បន្ន គណបក្សនយោបាយមានចំនួនសរុប ៤៤គណបក្ស ក្នុងនោះគណបក្សដែលបានចុះបញ្ជីចំនួន ៤១គណបក្ស និងគណបក្សដែលបានបង្កើតចំនួន០៣គណបក្ស។

## II-<u>បញ្ហាប្រឈម និងសំណូមពរ</u>

ទន្ទឹមនឹងការសម្រេចលទ្ធផលដូចខាងលើ ក្នុងការបំពេញភារកិច្ចកន្លងមក អគ្គនាយកដ្ឋានរដ្ឋបាលបានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

-ការបញ្ជូនឯកសារពីក្រសួងមហាផ្ទៃទៅកាន់រដ្ឋបាលរាជធានី ខេត្ត និងការបញ្ជូនឯកសារពីរដ្ឋបាល រាជធានីខេត្តមកក្រសួងមហាផ្ទៃនៅតែមានភាពយឺតយ៉ាវ។

-ការផ្គត់ផ្គង់សម្ភារៈការិយាល័យដូចជាក្រដាសទឹកថ្នាំ ម៉ាស៊ីនថតចម្លង ដើម្បីប្រើប្រាស់បំពេញការងារមិនគ្រប់គ្រាន់។

-ការផ្គត់ផ្គង់ប្រេងឥន្ធនៈ និងប្រាក់បេសកកម្មសម្រាប់មន្ត្រីចុះបំពេញការងារនៅតាមខេត្តមានភាពយឺតយ៉ាវបន្ទាប់ពីបញ្ចប់បេសកកម្ម មន្ត្រីរាជការត្រូវចំណាយថវិកាផ្ទាល់ខ្លួនជាមុន។

ដើម្បីជំរុញការអនុវត្តការងារឱ្យមានប្រសិទ្ធភាព ក៏ដូចជាការលើកទឹកចិត្តមន្ត្រី ក្នុងការបំពេញការងារ អគ្គនាយកដ្ឋានរដ្ឋបាល សំណូមពរដូចខាងក្រោម៖

-ផ្គត់ផ្គង់សម្ភារការិយាល័យឱ្យបានសមស្រប និងទាន់ពេលវេលាសម្រាប់បំពេញការងារ

-ផ្តល់ប្រេងឥន្ធនៈ និងប្រាក់បេសកកម្មឱ្យបានលឿនជាងមុនបន្ទាប់ពីចុះបេសកកម្ម។

## III-<u>ទិសដៅការងារបន្ត</u>

ដើម្បីជំរុញការអនុវត្តការងារឱ្យបានល្អប្រសើរ និងតាមផែនការដែលបានគ្រោងទុក អគ្គនាយកដ្ឋានរដ្ឋបាលបានដាក់ចេញនូវទិសដៅការងារបន្តសម្រាប់ខែធ្នូ ឆ្នាំ២០១៨ ដូចខាងក្រោម៖

**១-ការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត**

**១.១-លិខិតបទដ្ឋានគតិយុត្តិផ្ទៃក្នុងដែលកំពុងរៀបចំ**

-សេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋានការងាររបស់មន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះក្របខណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់អាសនៈក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌអាណត្តិទី៣

-សេចក្តីព្រាងអនុក្រឹត្យស្តីពីគោលការណ៍ និងនីតិវិធីនៃការបង្កើត ការលុបចោល ការកែសម្រួល និងការកំណត់ឈ្មោះរបស់រដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការដំឡើងប្រាក់បំណាច់មុខងារជូនមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីរបៀបរបបធ្វើការងាររបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលស្រុកដែលពុំទាន់មានការិយាល័យច្រកចេញចូលតែមួយ

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីនីតិវិធីនៃការផ្លាស់ប្តូរ និងតែងតាំងស្មៀនឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីនីតិវិធីនៃការសុំច្បាប់ឈប់សម្រាករបស់ប្រធានក្រុមប្រឹក្សានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីបែបបទ និងនីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីការចេញប័ណ្ណសម្គាល់ខ្លួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីនីតិវិធីបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាងសៀវភៅណែនាំស្តីពីនីតិវិធីនៃការសម្រុះសម្រួលដោះស្រាយបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋ

-សេចក្តីព្រាងសៀវភៅកិច្ចការរដ្ឋបាលសម្រាប់ប្រើប្រាស់នៅតាមអង្គភាព(ផ្នែករដ្ឋបាលស៊ីវិល) ចំណុះទីស្តីការក្រសួងមហាផ្ទៃ

-សេចក្តីព្រាងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៩- ២០២៨។

**១.២-លិខិតបទដ្ឋានគតិយុត្តិដែលសហការរៀបចំជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ**

- សេចក្តីព្រាងច្បាប់ស្តីពីសេវាសាធារណៈ
- សេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម
- សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃអង្គរដ្ឋបាលសម្រាប់មន្ត្រីរាជការស៊ីវិល

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលរចនាសម្ព័នរដ្ឋបាលក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រង ការបែងចែកចំណូលពីកម្រៃសេវារដ្ឋបាលរបស់អង្គភាពច្រកចេញចូលតែមួយ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែប្រែ និងដំឡើងប្រាក់បំណាច់មុខងារជូនមន្ត្រីរាជការស៊ីវិល ឆ្នាំ២០១៩

-សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការពិន័យអន្តរកាលចំពោះអំពើល្មើសនឹងអនុក្រឹត្យលេខ១១៣ស្តីពីការគ្រប់គ្រង់សំរាមសំណល់រឹងទីប្រជុំជន

-សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីសហព័ន្ធអាជីវកម្ម ឬ ពាណិជ្ជកម្ម ឬ សភាពាណិជ្ជកម្មបរទេស(ក្រសួងមហាផ្ទៃ និងក្រសួងពាណិជ្ជកម្ម)

-សេចក្តីព្រាងក្រមប្រតិបត្តិសម្រាប់អ្នករាជការសាធារណៈ។

**២-ការងារបុគ្គលិក**

**២.១-ការងារក្របខ័ណ្ឌ**

-កំណៅញ្ញាសាប្រឡងជ្រើសរើសសិស្ស និស្សិតឱ្យចូលបម្រើក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃក្នុងផែនការក្របខ័ណ្ឌឆ្នាំ២០១៨

-បន្តរៀបចំបែបបទសុំដំឡើងថ្នាក់ និងឋានន្តរស័ក្តិតាមកម្រិតសញ្ញាបត្រជូនមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ សម្រាប់ឆ្នាំ២០១៨

-បន្តរៀបចំបែបបទស្នើសុំផ្ទេរក្របខ័ណ្ឌពីមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ ទៅក្នុងក្របខ័ណ្ឌក្រសួង-ស្ថាប័នផ្សេងៗ និងពីក្របខ័ណ្ឌក្រសួង-ស្ថាប័នផ្សេងៗមកក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទដាក់មន្ត្រីរាជការឲ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម ដើម្បីទៅបំពេញការងារក្នុងមុខតំណែងថ្មី និងអនុញ្ញាតឲ្យមន្ត្រីរាជការចូលបម្រើការងារក្នុងក្របខ័ណ្ឌដើមវិញ

-បន្តរៀបចំបែបបទដើម្បីតាំងស៊ប់ជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទដើម្បីសុំពិនិត្យនីត្យានុកូលភាពលើប្រកាសតែងតាំង និងប្រគល់ភារកិច្ចដើម្បីស្នើសុំផ្តល់ប្រាក់បំណាច់មុខងារជូនមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទផ្តល់ទិដ្ឋាការលើសាលាកប័ត្រជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ។

**២.២-ការងារគោលនយោបាយមន្ត្រីរាជការស៊ីវិល**

-រៀបចំសេចក្តីជូនដំណឹងស្តីពីការដាក់មន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ ដែលដល់អាយុត្រូវចូលនិវត្តន៍ក្នុងឆ្នាំ២០១៩ ដល់អង្គភាពចំណុះទីស្តីការក្រសួងមហាផ្ទៃ និងតាមបណ្តាលរាជធានី-ខេត្តនីមួយៗ

-បន្តរៀបចំសំណុំលិខិតលុបឈ្មោះមន្ត្រីរាជការដែលទទួលមរណភាពនិងមន្ត្រីរាជការដែលសុំលាឈប់ពីការងារ

-បន្តរៀបចំការផ្តល់ប័ណ្ណសម្គាល់ខ្លួនជូនមន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ

-បន្តរៀបចំសំណុំលិខិតលុបឈ្មោះមន្ត្រីដែលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយហួសកាលកំណត់

-បន្តរៀបចំបែបបទដាក់មន្ត្រីរាជការឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សតាមការស្នើសុំ

-បន្តរៀបចំសំណុំលិខិតអនុញ្ញាត ឱ្យមន្ត្រីរាជការចូលបម្រើការងារនៅអង្គភាពដើមវិញ បន្ទាប់ពីសុំស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សតាមការស្នើសុំ

-បន្តរៀបចំសំណុំលិខិតអនុញ្ញាតឈប់សម្រាកលំហែមាតុភាព

-បន្តរៀបចំសំណុំបែបបទផ្ទេរកូនកំព្រា និងសុំប្រាក់ធានារ៉ាប់រងសង្គម

-បន្តពិនិត្យផ្ទៀងផ្ទាត់ការស្នើសុំគ្រឿងឥស្សរិយយស មេដាយការងារ និងប័ណ្ណសរសើរជូនមន្ត្រីរាជការស៊ីវិល។

**២.៣-ការងារបុគ្គលិករដ្ឋបាលថ្នាក់ជាតិ**

-បន្តសិក្សារៀបចំការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងមុខតំណែង និងចំនួនមន្ត្រីនៅតាមមុខតំណែងនៃអង្គភាពនីមួយៗ ផ្លាស់ប្តូរកន្លែងធ្វើ ការរៀបចំដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិរយៈពេល ០៣ខែ សម្រាប់មន្ត្រីរាជការស៊ីវិល និងដាក់ទណ្ឌកម្មខាងវិន័យសម្រាប់មន្ត្រីពន្ធនាគារ និងរៀបចំតារាងបៀវត្សកែតម្រូវឱ្យត្រូវតាមរចនាសម្ព័ន្ធនៃអង្គភាពនីមួយៗ

-បន្តរៀបចំធ្វើបច្ចុប្បន្នភាពសម្រាប់ខែបន្ទាប់របស់មន្ត្រីរាជការស៊ីវិលនិងមន្ត្រីពន្ធនាគារឱ្យមានភាពត្រឹមត្រូវនៅទីស្តីការក្រសួងមហាផ្ទៃ

-បន្តធ្វើការតែងតាំងទីប្រឹក្សា ជំនួយការសម្រាប់អាណត្តិថ្មី

-ត្រៀមដំណើរការបុគ្គលដែលត្រូវប្រកាសទ្រព្យសម្បត្តិតាមវេនប្រចាំឆ្នាំ២០១៩

-បន្តតាមដានបញ្ជីវត្តមានប្រចាំខែមន្ត្រីរាជការស៊ីវិល នៅទីស្តីការក្រសួងមហាផ្ទៃ។

**២.៤-ការងារបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

-ពិនិត្យ និងសិក្សាលើសំណើសុំកែសម្រួលរចនាសម្ព័ន្ធទីចាត់ការ អង្គភាព និងការិយាល័យនានា នៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-បន្តចូលរួមសហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការចុះពង្រឹងរបៀបរបបការងារ និងការគ្រប់គ្រងមន្ត្រីរាជការនៅតាមសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់

-បន្តសហការ និងសម្របសម្រួលជាមួយនឹងអង្គភាពប្រឆាំងអំពើពុករលួយ លើការងារប្រកាសទ្រព្យសម្បត្តិ និងបំណុល សម្រាប់ឆ្នាំ២០១៨

-ពិនិត្យ និងលើកយោបល់ ដើម្បីស្នើសុំការសម្រេចលើការតែងតាំងគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវដល់អាណត្តិ ០៤ឆ្នាំរបស់ខ្លួន

-បន្តធ្វើបច្ចុប្បន្នភាពបញ្ជីគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**២.៥-ការងារក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**

-បន្តយកចិត្តទុកដាក់ពិនិត្យលើកយោបល់ទាក់ទងការផ្លាស់ប្តូរ និងទទួលស្គាល់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ឱ្យបានទាន់ពេលវេលា

-បន្តធ្វើបច្ចុប្បន្នភាពបញ្ជីក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

-រៀបចំអនុក្រឹត្យកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-រៀបចំលិខិតបទដ្ឋាននានាសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាណត្តិទី៣។

**២.៦-ការងារគ្រប់គ្រងទិន្នន័យមន្ត្រីរាជការស៊ីវិល**

-កែតម្រូវស្ថានភាពព័ត៌មានមន្ត្រីរាជការនៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យសម្រាប់ខេត្តឧត្តរមានជ័យ

-ធ្វើបច្ចុប្បន្នភាពដោយកែតម្រូវស្ថានភាពព័ត៌មានមន្ត្រីរាជការនៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យសម្រាប់ខេត្តកំពង់ឆ្នាំង

-ធ្វើបច្ចុប្បន្នភាពដោយកែតម្រូវស្ថានភាពព័ត៌មានមន្ត្រីរាជការស៊ីវិលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិជាបន្តបន្ទាប់។

**៣-ការងារអភិវឌ្ឍន៍សមត្ថភាព**

**៣.១-ការងារអភិវឌ្ឍន៍សមត្ថភាពក្នុងប្រទេស**

-បន្តរៀបចំឯកសារបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

-រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងសម្រាប់នាយករដ្ឋបាលក្រុង ស្រុក ខណ្ឌនៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ (CKCC)រាជធានីភ្នំពេញ

-រៀបចំវគ្គបណ្តុះបណ្តាលក្រិត្យការមូលដ្ឋាន វគ្គអន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាព និងវគ្គក្រឹត្យការជំនាញ នៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

-រៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីប្រកាស និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាព មន្ត្រីរាជការស៊ីវិល នៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

-រៀចំវគ្គបណ្តុះបណ្តាលសម្រាប់ក្រុប្រឹក្សាឃុំ និងប្រជាពលរដ្ឋគោលដៅនៅខេត្តបាត់ដំបង ដោយសហកាជាមួយអង្គការ TI Cambodia ។

**៣.២-ការងារអភិវឌ្ឍន៍សមត្ថភាពក្រៅប្រទេស និងលិខិតឆ្លងដែន**

-បន្តរៀបចំបែបបទដើម្បីបញ្ជូនមន្ត្រីទៅចូលរួមសកម្មភាពអភិវឌ្ឍន៍សមត្ថភាពនៅក្រៅប្រទេស

-បន្តសហកាជាមួយដៃគូដើម្បីស្វែងរកការគាំទ្រ និងកិច្ចសហការសម្រាប់ការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទដើម្បីស្នើសុំលិខិតឆ្លងដែនការទូត និងផ្លូវការតាមការស្នើសុំពីមន្ត្រីរាជការទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**៣.៣-ការងារផ្សព្វផ្សាយ និងព័ត៌មាន**

- បន្តធ្វើបច្ចុប្បន្នភាពគេហទំព័រអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ

- បន្តបញ្ចូលព័ត៌មានលិខិតបទដ្ឋានគតិយុត្ត ទៅក្នុងគេហទំព័រអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ

- បន្តកែសម្រួលព្រឹត្តិបត្រវិមជ្ឈការ និងវិសហមជ្ឈការ ក្រសួងមហាផ្ទៃ លេខ៣ ឆ្នាំទី៣ ឆ្នាំ២០១៨

- បន្តស្រាវជ្រាវ និងសរសេរអត្ថបទដើម្បីបញ្ចូលទៅក្នុងព្រឹត្តិបត្រ «វិមជ្ឈការ និងវិសហមជ្ឈការ»។

-ជូនដំណឹងស្តីពីការចាត់មន្ត្រីរាជការ ០១នាក់ ទទួលខុសត្រូវលើការងារបុគ្គលិកជាមន្ត្រីបង្គោលដើម្បីធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការដែលបម្រើការងារក្នុងរចនាសម្ព័ន្ធគ្រប់អង្គភាព ចំណុះទីស្តីការក្រសួងមហាផ្ទៃតាមរយៈការចាត់មន្ត្រីបង្គោល ០១នាក់ នៅតាមការិយាល័យជំនាញនីមួយៗ ដើម្បីភ្ជាប់ទំនាក់ទំនងផ្តល់ទិន្នន័យ ព្រមទាំងព័ត៌មានសំខាន់ៗមួយចំនួនរបស់មន្ត្រីរាជការឱ្យបានឆាប់រហ័ស និងទាន់ពេលវេលា។

**៤-ការងារគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ**

**៤.១-ការងារគាំទ្រឯបច្ចេកទេស និងអន្តរាគមន៍**

-បន្តពិនិត្យ និងលើកយោបល់ ករណីស្នើសុំអន្តរាគមន៍ពីសម្តេចក្រឡាហោម ដើម្បីឱ្យក្រុមហ៊ុន Global Agricultural Development Co.,Ltd បានសហការជាមួយខេត្តក្រចេះក្នុងការពន្លឿនការអនុវត្តលិខិតលេខ ៧២០ សជណ.កស ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

-បន្តពិនិត្យ និងលើកយោបល់ ករណីឈ្មោះ **លឿន ផល្លីស** ធ្វើសេចក្តីរាយការណ៍ស្តីពីកិច្ចប្រជុំនៅសាលារាជធានីភ្នំពេញស្នើសុំអន្តរាគមន៍ពាក់ព័ន្ធនឹងការប្រមូលកាស៊ីផ្សារនៅរាជធានីភ្នំពេញ

-បន្តពិនិត្យ និងលើកយោបល់ ករណីតំណាងប្រជាពលរដ្ឋ១៤២គ្រួសារ រស់នៅភូមិព្រៃកក្របៅទី២ ឃុំព្រៃកអំពិល ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាលស្នើសុំប្តឹងលោក**ព្រឿង សឿន**ដែលមានតួនាទីជាមេភូមិព្រៃក្របៅទី២ដោយសុំដកចេញពីតួនាទី។

-បន្តពិនិត្យនិងលើកយោបល់ ករណីរដ្ឋបាលខេត្តចំនួន ០៨ ស្នើសុំបង្កើតនិងប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលខេត្ត រួមមាន៖ ខេត្តកំពង់ចាម កំពង់ស្ពឺ កំពង់ធំ កណ្តាល ព្រះសីហនុ ស្វាយរៀង តាកែវ និងខេត្តប៉ៃលិន។

-បន្តពិនិត្យ និងលើកយោបល់ ករណីរដ្ឋបាលខេត្តព្រៃវែង ស្នើសុំកាត់ដីទំហំ ៧,០១៣ម៉ែត្រការ៉េរបស់ការិយាល័យគ្រឿងយន្តស្ថិតនៅភូមិលេខ៤ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែងចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិ នៃមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្តជូនមន្ទីរកិច្ចការនារី មន្ទីរធម្មការ និងសាសនា មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរព័ត៌មាន សាលាសង្កាត់កំពង់លាវ ប៉ុស្តិ៍នគរបាលរដ្ឋបាលកំពង់លាវ និងកងរាជអាវុធហត្ថក្រុងព្រៃវែង។

-បន្តពិនិត្យនិងលើកយោបល់ ករណីចាត់មន្ត្រីជំនាញចូលរួមក្នុងគណៈកម្មការអន្តរក្រសួង ដើម្បីចុះពិនិត្យវាយតម្លៃអចលនទ្រព្យរបស់រដ្ឋ ចំពោះការដោះដូរទីតាំងដីមួយផ្នែកនៃស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ ជាថ្នូរនឹងការសាងសង់អគារនៅលើដីស្នងការដ្ឋាន ស្ថិតនៅភូមិត្រស់សាលា សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ។

-បន្តពិនិត្យ និងលើកយោបល់ ករណីឈ្មោះ **សេង សជ្ជតា** ស្នើសុំជួយអន្តរាគមន៍មោឃភាពលិខិតលេខ ៦៦០/១៨ចត.ន ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨របស់រដ្ឋបាលរាជធានីភ្នំពេញ ដែលសម្រេចប្រគល់ដីជាទ្រព្យសម្បត្តិរួមសហព័ន្ធរបស់ឈ្មោះ សេង សជ្ជតាឱ្យទៅឈ្មោះ **លឹម វណ្ណ** កាន់កាប់។

-បន្តពិនិត្យ និងលើកយោបល់ ករណីស្នើសុំដោះស្រាយបញ្ហាដែលចុះផ្សាយក្នុងគេហទំព័រ និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ៖

• លោកឈួរ **ច័ន្ទឌឿន** អភិបាលខេត្តកំពង់ឆ្នាំងរងការរិះគន់រឿងមិនបង្រ្កាបបទល្មើសព្រៃឈើ និងបទល្មើសជលផល

• ព្រៃឡង់ក្នុង ស្រុកសណ្តាន់ ខេត្តកំពង់ធំ នៅតែរងការបំផ្លាញយ៉ាងពេញបន្ទុកព្រោះមានការឃុបឃិតជាប្រព័ន្ធ។

-បន្តពិនិត្យ និងលើកយោបល់ ករណីរដ្ឋបាលខេត្តក្រចេះស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលរាជធានី ខេត្តចំនួន ១៥ ចូលរួមធ្វើអត្តសញ្ញាណកម្មគ្រួសារប្រជាពលរដ្ឋ ដែលអាចទទួលបានសម្បទានដីសង្គមកិច្ច ស្ថិតក្នុងឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ។

-បន្តពិនិត្យ និងលើកយោបល់ ករណីឈ្មោះ សៀ សាហេន, ណែម រី, ខ្វាន់ ដារ៉ា, ណុប ស៊ីផាន់, នឹង វណ្ណារ៉ា, ពេជ ទេព,ពេជ ចាន់ និងរើន រុណ ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលខេត្តសៀមរាប និងជំនាញពាក់ព័ន្ធឱ្យជួយចេញប័ណ្ណកម្មសិទ្ធិស្របច្បាប់នូវក្បាលដីលេខ ៣៨៤, ០៩, ៣៨២, ២៩៥, ៣០៥, ៣០៦, ៣១០, ៣១១ និង៣១៣ ស្របតាមអនុក្រឹត្យលេខ ១៥៨ អនក្រ.បក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការផ្តើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះដាក់ស្តែង នៅក្នុងបុរីសណ្ឋាគារអង្គរសៀមរាប។

-បន្តពិនិត្យ លើកយោបល់ ករណីស្ថានទូតរុស្ស៊ីប្រចាំកម្ពុជាស្នើសុំអាជ្ញាធរពាក់ព័ន្ធកម្ពុជាចាត់វិធានការសមស្រប ដើម្បីជួយដោះស្រាយបញ្ហាសន្តិសុខ សណ្តាប់ធ្នាប់ និងបរិស្ថាននៅទីជុំវិញបរិវេណស្ថានទូត។

-បន្តរៀបចំបូកសរុបរបាយការណ៍លទ្ធផលការងារប្រចាំខែរបស់រដ្ឋបាលរាជធានី ខេត្ត។

-ត្រៀមរៀបចំសម្របសម្រួលដល់ដំណើរការរៀបចំសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៨ និងលើកទិសដៅការងារប្រចាំឆ្នាំ២០១៩ របស់រដ្ឋបាលរាជធានី ខេត្ត។

-បន្តរៀបចំបូកសរុបរបាយការណ៍លទ្ធផលការងារប្រចាំខែរបស់រដ្ឋបាលរាជធានី ខេត្ត។

### ៤.២-ការងារបង្កើត កែសម្រួល និងកំណត់ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ

-បន្តពិនិត្យ និងលើកយោបល់ ករណីរដ្ឋបាលខេត្តកណ្តាលស្នើសុំកាត់ផ្ទេរឃុំចំនួន ០៤ ស្ថិតក្នុងស្រុកស្អាងព្រមទាំងផ្ទៃដីមួយផ្នែកទៀតនៃស្រុកកណ្តាលស្ទឹងមកបញ្ចូលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុងតាខ្មៅ ខេត្តកណ្តាល។

-បន្តពិនិត្យ និងលើកយោបល់ ករណីរដ្ឋបាលខេត្តព្រះសីហនុស្នើសុំបង្កើតក្រុងកោះរ៉ុង ដោយបំបែកចេញពីក្រុងព្រះសីហនុ រួមជាមួយនឹងសំណើសុំកាត់ឃុំចំនួនពីរគឺ ឃុំរាម ឃុំបិតត្រាំង ពីស្រុកព្រៃនប់ ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុងព្រះសីហនុ និងកែសម្រួលព្រំប្រទល់រដ្ឋបាលឃុំអូរត្រេះ ស្រុកស្ទឹងហាវ និងសង្កាត់លេខ១ ក្រុងព្រះសីហនុ ដោយកាត់យកផ្ទៃដីមួយផ្នែកនៃឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុមកបញ្ចូលក្នុងសង្កាត់លេខ១ ក្រុងព្រះសីហនុ។

-បន្តពិនិត្យ និងលើកយោបល់ ករណីរដ្ឋបាលខេត្តកំពត ស្នើសុំកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងក្រុងកំពត និងស្រុកទឹកឈូ ក្នុងភូមិសាស្ត្រខេត្តកំពត។

-បន្តពិនិត្យ និងលើកយោបល់ ករណីរដ្ឋបាលខេត្តកំពង់ធំ ស្នើសុំបំបែកស្រុកបារាយណ៍ជាពីរ។

-បន្តពិនិត្យ និងលើកយោបល់ ករណីរដ្ឋបាលខេត្តព្រៃវែង ស្នើសុំកាត់ឃុំតាកោ ពីស្រុកពោធិ៍រៀងបញ្ចូលក្នុងរដ្ឋបាលដែនដីក្រុងព្រៃវែង។

-បន្តពិនិត្យ និងលើកយោបល់ ករណីរដ្ឋបាលខេត្តស្ទឹងត្រែងស្នើសុំបង្កើតស្រុកបុរីអូរស្វាយសែនជ័យ។

-បន្តពិនិត្យ និងលើកយោបល់ ករណីរដ្ឋបាលខេត្តព្រះវិហារស្នើសុំបង្កើតស្រុកថ្មីចំនួន ០១ និងកំណត់ព្រំប្រទល់រដ្ឋបាលរវាងឃុំ និងឃុំ ស្រុក និងស្រុក។

### ៤.៣-ការងារផ្តល់គោរមងារ គ្រឿងឥស្សរិយយស និងមេដាយស្ថាបនាជាតិ

-បន្តតាមដាន ត្រួតពិនិត្យអំពីការអនុវត្តលិខិតលេខ១៩៧៣ស.ជ.ណ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការពង្រឹងការគ្រប់គ្រង ការស្នើសុំគ្រឿងឥស្សរិយយសស្ថាបនាជាតិ និងគោរមងារជាឧកញ៉ាជូនសប្បុរសជនដែលមានស្នាដៃ និងគុណបំណាច់ក្នុងការជួយកសាងជាតិក្នុងព្រះរាជាណាចក្រកម្ពុជា

-បន្តពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួង ករណីសំណើសុំគ្រឿងឥស្សរិយយសរបស់រដ្ឋបាលខេត្តព្រៃវែង ស្វាយរៀង ឧត្តរមានជ័យ បាត់ដំបង និងខេត្តសៀមរាប ។

### ៤.៤-ការងារសម្របសម្រួល និងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងគម្រោងនានា

#### ៤.៤.១-កម្មវិធីគាំទ្រដោយអង្គការ UNICEF

- ចុះតាមដានការអនុវត្តសកម្មភាពសេវាសង្គមនៅរាជធានី និងខេត្តគោលដៅ
- រៀបចំផែនការសកម្មភាព និងថវិកាត្រីមាសទី៤ ឆ្នាំ២០១៨ ដែលគាំទ្រដោយ UNICEF
- ជំរុញរដ្ឋបាលរាជធានី ខេត្ត គោលដៅក្នុងការផ្តល់របាយការណ៍សកម្មភាព និងថវិកាត្រីមាសទី៣។
- ប្រមូល និងសរុបរបាយការណ៍វគ្គបណ្តុះបណ្តាលសៀវភៅណែនាំស្តីពីការអនុវត្តសេវាសង្គមឃុំ សង្កាត់ នៅរដ្ឋបាលរាជធានី ខេត្តគោលដៅ។

#### ៤.៤.២-កម្មវិធីគាំទ្រដោយអង្គការ TIC

- បន្តតាមដាន និងជំរុញការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងដំណើរការអភិវឌ្ឍន៍របស់រដ្ឋបាលស្រុក ឃុំ
- បន្តចូលរួមបើកវេទិកាសាធារណៈស្តីអំពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការរៀបចំ និងការអនុវត្តថវិកានៅថ្នាក់ក្រោមជាតិ ដល់រដ្ឋបាលឃុំបន្ទាយឆ្មារ និងរដ្ឋបាលស្រុកថ្មពួក នៅខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប។

#### ៤.៤.៣-កម្មវិធីគាំទ្រដោយវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល GGGI

បន្តពិនិត្យ និងកែសម្រួលសេចក្តីព្រាងផែនការយុទ្ធសាស្ត្រទីក្រុងនិរន្តរភាពឆ្នាំ២០១៨ ជាមួយក្រសួងបរិស្ថាន។

#### ៤.៤.៤-គម្រោងសាងសង់អគាររដ្ឋបាល និងអាគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់ DCOCP

-បន្តចុះពិនិត្យទីតាំងសម្រាប់សាងសង់របស់ស្រុក និងឃុំ សង្កាត់គោលដៅ ដំណាក់កាលទី២

-រៀបចំរបាយការណ៍ នៃសិក្សាអង្កេតវាស់វែងទីតាំងសាងសង់ ដំណាក់កាលទី២

-បន្តរៀបចំទ្រឹស្តីបច្ចេកទេសសម្រាប់ការសាងសង់អគាររដ្ឋបាលក្រុង ស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់

-រៀបចំរបាយការណ៍នៃការចាប់ផ្តើមអនុវត្តគម្រោង។

### ៤.៥-ការងាររដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់

- បន្តប្រមូលទិន្នន័យគម្រោងក្រុង ស្រុក ឃុំ សង្កាត់ពីតាមបណ្តារាជធានី ខេត្ត
- បន្តតាមដាន ត្រួតពិនិត្យការអនុវត្តគម្រោងមូលនិធិក្រុង ស្រុក ឃុំ សង្កាត់ ២០១៨-២០២០
- បន្តធ្វើបច្ចុប្បន្នភាពដំណើរការកសាងកម្មវិធីវិនិយោគក្រុង ស្រុក ឃុំ សង្កាត់ឆ្នាំ២០១៨-២០២០ និងឆ្នាំ២០១៩-២០២១
- បន្តធ្វើបច្ចុប្បន្នភាពដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ២០១៧-២០២២។

### ៤.៦-ការផ្តល់សេវានៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលទូទៅដល់មន្ត្រីការិយាល័យច្រកចេញចូលតែមួយស្រុកគោលដៅថ្មីទាំង ៣១ ក្នុងឆ្នាំ២០១៨

-ត្រៀមរៀបចំកម្មវិធីសម្ពោធ និងដាក់ឱ្យដំណើរការជាផ្លូវការ នូវអង្គភាពច្រកចេញចូលតែមួយទាំង២៥ រាជធានី ខេត្ត

-ត្រៀមរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ផ្ទៃក្នុង នៃអគ្គនាយកដ្ឋានរដ្ឋបាល លើសេចក្តីព្រាងសេចក្តីណែនាំស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយ សម្រាប់ផ្តល់សេវារដ្ឋបាល នៅថ្នាក់ស្រុកដែលពុំទាន់មានការិយាល័យច្រកចេញចូលតែមួយ

-ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលជំហានទី២ ស្តីពីបច្ចេកទេសនៃការផ្តល់សេវារដ្ឋបាលនៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត

-តាមដានគាំទ្រការបង្កើត និងដំណើរការអង្គភាពច្រកចេញចូលតែមួយ យន្តការច្រកចេញចូលតែមួយ និងការិយាល័យច្រកចេញចូលតែមួយ។

**៥-ការងារសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពនានា**

-បន្តពិនិត្យលើកយោបល់ ករណីការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជាអញ្ជើញអភិបាល នៃគណៈអភិបាលខេត្តក្រចេះ ឬតំណាង និងចាត់មន្ត្រីជំនាញចូលរួមសិក្ខាសាលាស្តីពី "ធុរកិច្ច និងសិទ្ធិមនុស្ស" នៅខេត្តក្រចេះ។

-បន្តពិនិត្យ និងលើកយោបល់ ករណីក្រសួងពាណិជ្ជកម្មស្នើសុំបច្ចុប្បន្នភាពឈ្មោះភូមិ ឃុំ សង្កាត់ រាជធានី ខេត្ត ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីកែសម្រួលអាសយដ្ឋានក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មនៃការចុះបញ្ជីពាណិជ្ជកម្មឱ្យបានពេញលេញ។

-បន្តពិនិត្យ និងលើកយោបល់ ករណីវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាធ្វើរបាយការណ៍ស្តីពីការចុះអង្កេតលើគម្រោងស្រាវជ្រាវចំនួន ១២លើក ចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៧។

-បន្តពិនិត្យ និងលើកយោបល់ ករណីក្រសួងបរិស្ថានស្នើសុំចាត់បញ្ជូនមន្ត្រីជាន់ខ្ពស់ ដែលមានសិទ្ធិសម្រេចចំនួន ០២រូប ដើម្បីចូលរួមជាសមាជិកគណៈកម្មការអន្តរក្រសួង ដើម្បីសម្របសម្រួលនិងដោះស្រាយបញ្ហាវិវាទនៅក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន Union Development Group Co.,Ltd ខេត្តកោះកុង។

-បន្តចូលរួមសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីសិក្សា ពិនិត្យលើកយោបល់ និងផ្តល់ធាតុចូលលើសេចក្តីព្រាងកិច្ចព្រមព្រៀងស្តីពី "ពាណិជ្ជកម្មតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម"។

**៦-ការងារតាមវិស័យផ្សេងៗ**

**៦.១-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន**

-បន្តធ្វើការបូកសរុប និងសិក្សាលើកយោបល់ពាក់ព័ន្ធនឹងសកម្មភាពទូទៅរបស់ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនក្នុងបណ្តាខេត្តជាប់ព្រំដែនជាមួយប្រទេសជិតខាង។

-បន្តពិនិត្យ លើកយោបល់ ករណីរដ្ឋបាលខេត្តក្រចេះស្នើសុំសាងសង់ស្ពានឆ្លងកាត់ព្រែកជីម៉ាំង នៅទីតាំងច្រកទ្វារព្រំដែនទ្វេភាគីជ័យឃ្លាំង(កម្ពុជា)-ទិនទៀង(វៀតណាម)។

-បន្តពិនិត្យលើកយោបល់ លើករណីរដ្ឋបាលខេត្តពោធិ៍សាត់ស្នើសុំគោលការណ៍អនុញ្ញាតឱ្យឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ ដឹកនាំគណៈប្រតិភូខេត្ត ទៅចូលជួបប្រជុំពិភាក្សាជាមួយខេត្តត្រាតនៃព្រះរាជាណាចក្រថៃ

-បន្តពិនិត្យ លើកយោបល់ ករណីរដ្ឋបាលខេត្តស្នើសុំអនុញ្ញាតឱ្យបន្ថែមម៉ោងបើកដំណើរការច្រកទ្វារព្រំដែនអន្តរជាតិចាំយាម ក្នុងអំឡុងពេលប្រារព្ធព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក និងពិធីបុណ្យសមុទ្រលើកទី៧ជុំទី២ នៅខេត្តកោះកុង។

-បន្តសម្របសម្រួលកិច្ចការនានា ដើម្បីរៀបចំការសាងសង់អគារ និងហេដ្ឋារចនាសម្ព័ន្ធទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិមិនជ័យ ស្ថិតក្នុងឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង។

-បន្តសម្របសម្រួលរៀបចំកិច្ចប្រជុំក្រុមការងារអន្តរក្រសួង ដើម្បីបង្កើត និងដំឡើងកម្រិតច្រកទ្វារព្រំដែនក្នុងបណ្តាខេត្តជាប់ព្រំដែនវៀតណាម។

-បន្តសិក្សាអំពីលទ្ធភាពក្នុងការពង្រីកការផ្តល់ប័ណ្ណព្រំដែនថ្នាក់រដ្ឋបាលក្រុង ស្រុក និងនៅច្រកទ្វារព្រំដែន។

-បន្តតាមដាន និងគាំទ្រដល់រដ្ឋបាលខេត្តជាប់ព្រំដែនថៃ និងខេត្តជាប់ព្រំដែនឡាវដល់ដំណើរការផ្តល់ប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋខ្មែរនៅតាមបណ្តាខេត្តជាប់ព្រំដែនថៃ និងខេត្តជាប់ព្រំដែនឡាវប្រើប្រាស់

-សិក្សាលទ្ធភាពក្នុងការផ្តល់សេវាប័ណ្ណព្រំដែននៅក្រុង ស្រុក និងច្រកនៃបណ្តាខេត្តជាប់ព្រំដែនថៃ និងខេត្តជាប់ព្រំដែនឡាវ។

-ត្រៀមសម្របសម្រួលរៀបចំកិច្ចប្រជុំលើកទី១០ ស្តីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍរវាងបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម និងកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃលើកទី៧។

-រាជរដ្ឋាភិបាលថៃ ស្នើរៀបចំពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការនូវច្រកទ្វារព្រំដែនចំនួន ០៤ក្រោមអធិបតីភាពនាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរ(កម្ពុជា-ថៃ)ក្នុងនោះរួមមាន៖ ១.ច្រកទ្វារតំបន់ព្រំដែនភ្នំដី (ខេត្តបាត់ដំបង)-បានខាវឌិន (ខេត្តស្រះកែវ)២.ច្រកទ្វារតំបន់ព្រំដែនអានសេះ(ខេត្តព្រះវិហារ)-អានម៉ា(ខេត្តឧប៊ុនរាជធានី)៣.ច្រកទ្វារតំបន់ព្រំដែនថ្មដា (ខេត្តពោធិ៍សាត់)-បានថាសែន(ខេត្តត្រាត)និង៤.ច្រកទ្វារតំបន់ព្រំដែនជប់គគីរ (ខេត្តឧត្តរមានជ័យ)-សាយតាគូរ(ខេត្តបុរីរ៉ាំ)។

-រដ្ឋបាលខេត្តប៉ៃលិន ករណីស្នើសុំសាងសង់ស្ពាននៅទីតាំងច្រកទ្វារព្រំដែនអន្តរជាតិព្រំ(កម្ពុជា)-បានប៉ាក់កាត(ថៃ)។

**៦.២-ការងារចងសម្ព័ន្ធមេត្រីភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

-រដ្ឋបាលរាជធានីភ្នំពេញ ករណីសុំបង្កើតចំណងសម្ព័នមេត្រីភាពជាមួយរដ្ឋធានីអង់ការ៉ា នៃសាធារណៈរដ្ឋទួរគី។

-បន្តពិនិត្យ លើកយោបល់លើ ករណីរដ្ឋបាលខេត្តត្បូងឃ្មុំស្នើសុំគោលការណ៍ទទួលស្គាល់អនុស្សរណៈនៃកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលខេត្តត្បូងឃ្មុំ និងគណៈកម្មាធិការប្រជាជនខេត្តតៃនិញ។

-បន្តពិនិត្យ លើកយោបល់លើ ករណីរដ្ឋបាលខេត្តកោះកុងស្នើសុំគោលការណ៍អនុញ្ញាតឱ្យ៖

• លោក **លី យ៉ាន** លេខាធិការរងគណៈកម្មាធិការប្រជាជនក្រុងស៊ីពីង ខេត្តជីលីន នៃសាធារណរដ្ឋប្រមានិតចិន និងប្រតិភូមកបំពេញទស្សនកិច្ចនៅខេត្តកោះកុង

• ប្រតិភូខេត្តកោះកុង ទៅចូលរួមក្នុងវេទិកាស្តីពី "ការផ្លាស់ប្តូរឧស្សាហកម្ម និងការអភិវឌ្ឍកិច្ចសហប្រតិបត្តិការអន្តរជាតិលើគម្រោងខ្សែក្រវ៉ាត់ និងផ្លូវ" នៅទីក្រុងថៃយៀន ខេត្តសានស៊ី នៃសាធារណរដ្ឋប្រជាមានិតចិន។

-បន្តពិនិត្យ លើកយោបល់លើចំពោះករណីឯកឧត្តម **Macharia Kamau** អនុរដ្ឋមន្ត្រីក្រសួងការបរទេសកេនយ៉ា បានផ្ញើលិខិតអញ្ជើញឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម និងឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តក្រចេះចូលរួមសន្និសីទសកលលើកទី១ ស្តីពីសេដ្ឋកិច្ចខៀវប្រកបដោយចីរភាព។

-បន្តពិនិត្យលើកយោបល់ ករណីរដ្ឋបាលខេត្តកែបស្នើសុំគោលការណ៍អនុញ្ញាតឱ្យលោក **អ៊ឹង ឆាយ** អភិបាលរង នៃគណៈអភិបាលខេត្ត ដឹកនាំប្រតិភូខេត្តចូលរួមក្នុងសន្និបាត សមុទ្រអាស៊ីបូព៌ា និងវេទិកាបណ្តាញរដ្ឋបាលមូលដ្ឋាននៃអង្គការ PEMSEA ប្រចាំឆ្នាំ២០១៨ ដែលនឹងប្រព្រឹត្តទៅនៅទីក្រុង Iloilo ប្រទេសហ្វីលីពីន។

-បន្តពិនិត្យ លើកយោបល់ ករណីរដ្ឋបាលខេត្តកំពង់ចាមស្នើសុំគោលការណ៍អនុញ្ញាតឱ្យប្រតិភូខេត្តទៅចូលរួមវេទិកាក្រុងសានយ៉ាឆ្នាំ២០១៨ ស្តីពីកិច្ចសហប្រតិបត្តិការ នៃបណ្តាក្រុងទេសចរណ៍មេគង្គ-ឡានឆាង នៅក្រុងសានយ៉ា ខេត្តហៃណាន នៃសាធារណរដ្ឋប្រជាមានិតចិន។

-បន្តពិនិត្យ លើកយោបល់ ករណីរដ្ឋបាលខេត្តរតនគិរីស្នើសុំគោលការណ៍អនុញ្ញាតឱ្យគណៈប្រតិភូខេត្តទៅចូលរួមក្នុងពិធីទំនាក់ទំនងព្រំដែនមិត្តភាពកម្ពុជា-ឡាវ-វៀតណាម នៅខេត្តកន្ទុមនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីពង្រឹង និងពង្រីកចំណងទំនាក់ទំនងមិត្តភាពកិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមកលើគ្រប់វិស័យ។

-បន្តធ្វើការបូកសរុប និងសិក្សាលើកយោបល់ពាក់ព័ន្ធ ករណីអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ ស្នើសុំផ្តល់របាយការណ៍អំពីលទ្ធផលទាំងក្នុងនិងក្រៅក្របខ័ណ្ឌ នៃការអនុវត្តកំណត់ហេតុកិច្ចសហប្រតិបត្តិការឆ្នាំ២០១៨ និងទិសដៅផែនការសហប្រតិបត្តិការឆ្នាំ២០១៩ រវាងក្រសួងមហាផ្ទៃកម្ពុជា និងក្រសួងសន្តិសុខសាធារណៈឡាវ ក្រសួងមហាផ្ទៃកម្ពុជា និងក្រសួងនគរបាលវៀតណាម។

-ស្ថានទូតរុស្ស៊ីប្រចាំនៅកម្ពុជា ករណីស្នើសុំអាជ្ញាធរពាក់ព័ន្ធកម្ពុជាចាត់វិធានការសមស្របដើម្បីជួយដោះស្រាយបញ្ហាសន្តិសុខសណ្តាប់ធ្នាប់ និងបរិស្ថាននៅជុំវិញបរិវេណស្ថានទូត។

**៦.៣-ការងារវិនិយោគ អភិវឌ្ឍន៍ និងអន្តរវិស័យ**

-បន្តលើកយោបល់សំណើផ្តល់អនុលោមភាពគម្រោងអភិវឌ្ឍរបស់រដ្ឋបាលរាជធានី ខេត្ត ឆ្នាំ២០១៨។

-ចុះត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តគម្រោងអភិវឌ្ឍ២០១៨ របស់រដ្ឋបាលរាជធានី ខេត្ត ក្នុងអំឡុងពេលអនុវត្តគម្រោង។

-បន្តពិនិត្យ និងលើកយោបល់ ករណីការផ្ទេរគម្រោងវិនិយោគរបស់ក្រុមហ៊ុនប្រតិបត្តិករអចលនទ្រព្យខ្មែរ ឯ.ក ក្នុងការវិនិយោគប្រព័ន្ធប្រឡាយបេតុងអាងប្រព្រឹត្តកម្មស្ថានីយបូមទឹកខ្នាតធំ ជាថ្នូរនឹងផ្ទៃដីអាងស្តុកទឹកបឹងជើងឯក ដើម្បីអភិវឌ្ឍន៍ទៅជាមជ្ឈមណ្ឌលពាណិជ្ជកម្ម តំបន់លំនៅឋាន មន្ទីរពេទ្យសាលារៀន និងសួនបៃតង ជូនក្រុមហ៊ុន ING Holding Co.,Ltd។

-បន្តពិនិត្យ លើកយោបល់ ករណីក្រសួងពាណិជ្ជកម្មស្នើសុំចាត់បញ្ជូនឯកឧត្តម លោកជំទាវ ឬមន្ត្រីថ្នាក់ដឹកនាំជំនាញឱ្យចូលរួមសមាសភាពគណៈកម្មការគ្រប់គ្រងគម្រោងសម្រាប់អនុវត្តការសាងសង់ផ្សារព្រំដែនកម្ពុជា-វៀតណាម។

### ៦.៤-ការងារកិច្ចការសមាគម និងគណបក្សនយោបាយ

#### ៦.៤.១-ការងារកិច្ចការសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-បន្តអនុវត្តការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាល ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ

-បន្តលើកយោបល់អំពីការសុំចុះឈ្មោះ សុំបើកទីស្នាក់ការសាខា សុំទទួលស្គាល់ប្រធាន និងសមាសភាពថ្មីនៃរចនាសម្ព័ន្ធ សុំប្តូរទីស្នាក់ការកណ្តាល សុំប្តូរឈ្មោះ សុំធ្វើវិសោធនកម្មលក្ខន្តិកៈ សុំលុបឈ្មោះការផ្អាកសកម្មភាពសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលនិងសំណើផ្សេងៗដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យសម្រេច

-បន្តលើកយោបល់អំពីការសុំតម្កល់សំណុំឯកសារ អំពីការផ្លាស់ប្តូរសមាសភាពរចនាសម្ព័ន្ធ និងការធ្វើវិសោធន៍កម្មលក្ខន្តិកៈរបស់សហគមន៍ជនជាតិដើមភាគតិច

-បន្តធ្វើបច្ចុប្បន្នភាព និងបូកសរុបនូវរបាយការណ៍សកម្មភាពរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល បន្តតាមដាន ប្រមូលព័ត៌មានពីគ្រប់បណ្តាញព័ត៌មានសង្គមពាក់ព័ន្ធនឹងការធ្វើសកម្មភាពសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-បន្តចូលរួមកិច្ចប្រជុំរៀបចំយុទ្ធសាស្ត្រជាតិស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មឆ្នាំ ២០១៩-២០២៣

-ត្រៀមរៀបចំកិច្ចប្រជុំក្រុមការងាររបស់រាជរដ្ឋាភិបាល ដើម្បីសម្របសម្រួលដោះស្រាយសំណើ និងសំណូមពររបស់អង្គការសង្គមស៊ីវិល ដែលមានសមាសភាពមកពីក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

-ត្រៀមរៀបចំវេទិកាស្តីពីភាពជាដៃគូ រវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលលើកទី២ នៅក្នុងអំឡុងខែមករា ឆ្នាំ២០១៩ខាងមុខ។

-លើកយោបល់ស្នើសុំគោលការណ៍ ដើម្បីរៀបចំការធ្វើជំរឿនសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានតម្កល់សំណុំឯកសារ និងចុះបញ្ជីនៅក្រសួងមហាផ្ទៃ។

#### ៦.៤.២-ការងារគណបក្សនយោបាយ

-បន្តពិនិត្យ លើកយោបល់នូវរាល់សំណើពាក់ព័ន្ធការបង្កើត ការចុះបញ្ជី និងការផ្លាស់ប្តូរ ឬការប្រែប្រួលស្ថានភាពនានា របស់គណបក្សនយោបាយ

-បន្តតាមដាន ពិនិត្យបូកសរុបប្រមូលព័ត៌មានពីគ្រប់បណ្តាព័ត៌មានសង្គម និងរបាយការណ៍របស់រដ្ឋបាលរាជធានីខេត្ត ចំពោះគណបក្សនយោបាយ ដែលបានធ្វើសកម្មភាពផ្ទុយពីលក្ខន្តិកៈច្បាប់ ស្តីពីគណបក្សនយោបាយ និងលិខិតបទដ្ឋានគតិយុត្តជាធរមាននានា

-ពិនិត្យ និងលើកយោបល់ពាក់ព័ន្ធនឹងបណ្តឹងនានារបស់គណបក្សនយោបាយ

-រៀបចំធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះគណបក្សនយោបាយដែលបានបង្កើត ចុះបញ្ជី និងលុបឈ្មោះ

-ពិនិត្យ និងរៀបចំឯកសារពាក់ព័ន្ធដើម្បីរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយគណបក្សនយោបាយ ដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ ក្នុងគោបំណងផ្សព្វផ្សាយអនុវត្តច្បាប់ស្តីពីគណបក្សនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានា

-ពិនិត្យ និងរៀបចំបូកសរុបរបាយការណ៍ ស្តីពីសកម្មភាពសំខាន់ៗប្រចាំឆ្នាំរបស់គណបក្សនយោបាយ ។

អគ្គនាយក៤.

ប្រាក់ សំរឿន

<u>*ចម្លងជូន៖*</u>

*-ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ*
*(ជូនជ្រាបជាសេចក្តីរាយការណ៍)*
*-អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ*
*-អគ្គស្នងការដ្ឋាននគរបាលជាតិ*
*-អគ្គនាយកដ្ឋានកស្តុការ និងហិរញ្ញវត្ថុ*
*-អគ្គាធិការដ្ឋាន*
*-អគ្គនាយកដ្ឋានពន្ធនាគារ*
*-គ្រប់នាយកដ្ឋានចំណុះអ.រ.ប*
*"ដើម្បីជូនជ្រាប"*
*-ឯកសារ-កាលប្បវត្តិ*